# មិត្តនគរបាល
POLICEFRIENDSHIPMAGAZINE


ទស្សនាវដ្ដី

លេខ ១០៥/ ឧសភា-មិថុនា / ២០២២


## អររគុណសន្តិភាព









យើងត្រូវរួមគ្នាទៅទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ១៩ តាមការកំណត់របស់ រាជរដ្ឋាភិបាលផង រួមគ្នាបន្តអនុវត្ត ៣ការពារ និង ៣កុំ ផង ដើម្បីខ្លួនយើង ក្រុមគ្រួសារយើង និងសង្គមជាតិយើង

# គណៈកម្មការនិពន្ធ

**នាយកគ្រប់គ្រង**

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ប៊ុនណារិន**

**និពន្ធនាយក**

ឧត្តមសេនីយ៍ឯក សៀង សុវត្ថិ

**និពន្ធនាយករង**

ឧត្តមសេនីយ៍ទោ ប៉ុក សុជាតិ

វរសេនីយ៍ឯក ប៉ុក រដ្ឋា



**យកព័ត៌មាន និពន្ធ**

-វរសេនីយ៍ទោ ចាប ភ័ស្ត (ប្រធានក្រុម)
-វរសេនីយ៍ត្រី ប៉ុក គន្ធារ៉ូ
-អនុសេនីយ៍ឯក គន សេរី

**ថតរូប**

-វរសេនីយ៍ទោ ជិន ម៉ូលីដា (ប្រធានក្រុម)
-អនុសេនីយ៍ឯក ស្រ៊ុ ឈុនឡេង
-អនុសេនីយ៍ឯក លន់ ឈាងសេង
-អនុសេនីយ៍ឯក ព្រំ ចាន់តារា

**ចែកផ្សាយ**

-វរសេនីយ៍ទោ ង៉ាន សុផាប (ប្រធានក្រុម)
-វរសេនីយ៍ត្រី សុន សៀង

**រចនាទំព័រ**

-អនុសេនីយ៍ឯក ម៉ុង រិទ្ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក អ៊ុន ពិសិទ្ធ

**ពិនិត្យអក្ខរាវិរុទ្ធ**

-វរសេនីយ៍ទោ ញឹម ហឿន (ប្រធានក្រុម)
-អនុសេនីយ៍ឯក វ៉ាន់ វិបុល

**កីឡា និងសិល្បៈ**

-វរសេនីយ៍ត្រី ជឹម ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក មុត សីហា





# មាតិកា

## ព័ត៌មានថ្នាក់ដឹកនាំ


១-សម្តេចក្រឡាហោម សម្ពោធដាក់ឱ្យប្រើប្រាស់........០១

២-សម្តេចក្រឡាហោមអនុញ្ញាតឱ្យលេខាធិការ...........០៥

៣-អគារសិក្សា ១ខ្នង ១០បន្ទប់ នៅអនុវិទ្យាល័យ..........០៧

៤-សម្តេចក្រឡាហោមស្នើឱ្យក្រុមហ៊ុន ស៊ី ភី..............១១

៥-ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត..................១៥

៦-វេទិការំទូក និងសំណង់សិល្បការផ្សេងៗស្ថិត..........១៩

៧-សម្តេចក្រឡាហោម ទោះយើងមានកម្លាំង...............២៣

៨-សម្តេចក្រឡាហោម ពិនិត្យសំណង់អគារ................២៧

៩-ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត..................៣១

១០-ប្រធាន គ ស ហ ស្នើតំណាងអង្គទូត និង................៣៣

១១-ទិវាអន្តរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន............៣៥

១២-សម្តេចក្រឡាហោមទទួលជួបពិភាក្សាការងារ........៣៩

១៣-សិក្ខាកាមនគរបាលជាតិ២០០នាក់បញ្ចប់វគ្គ..........៤៣

១៤-ពិធីប្រគល់សញ្ញាបត្រជូនមន្ត្រីនគរបាលជាតិ.........៤៧

១៥-លក្ខណៈសម្បត្តិ៦យ៉ាងដែលភ្នាក់ងារសន្តិសុខ.........៥១

១៦-សម្តេចក្រឡាហោម អញ្ជើញប្រគល់...................៦១


## សកម្មភាពសមាគមមិត្តនគរបាលជាតិកម្ពុជា


**១- ប្រគល់ថវិកា ស ម ន...................................................៥៣**


## អត្ថបទស្រាវជ្រាវ


**១-តើស្រីលង្កា ដោះស្រាយវិបត្តិសេដ្ឋកិច្ចរបស់ខ្លួនដោយ.............៥៥**

# សម្តេចក្រឡាហោម សម្ពោធ
# ស្ថិតក្នុងឃុំកំពង់ពពិល



នាព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះជួយខេត្តព្រៃវែង បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ **ផ្សារកំពង់ពពិល** ស្ថិតក្នុងឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង ។









**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

# ដាក់ឲ្យប្រើប្រាស់ផ្សារកំពង់ពពិល
## ស្រុកពារាំង ខេត្តព្រៃវែង



ឯកឧត្តម **ជា សុមេធី** អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង បានបញ្ជាក់ថា៖ ផ្សារកំពង់ពពិលកន្លងមក ត្រូវរងខូចខាតស្ទើរតែទាំងស្រុង ដោយគ្រោះអគ្គិភ័យកាលពីខែវិច្ឆិកា ឆ្នាំ២០២០ ។ ទន្ទឹមនេះដោយសារការខ្វះខាតក្រុមអាជីវករបានគោរពស្នើសុំ **សម្តេចក្រឡាហោម** ជួយសាងសង់ផ្សារនេះជាថ្មីឡើងវិញ ដោយ **សម្តេច** បានឯកភាពភ្លាមៗតាមសំណើរបហូតឈានដល់ការបញ្ចុះបឋមសិលាសាងសង់កាលពីខែកុម្ភៈ ឆ្នាំ២០២១ និងបានសាងសង់រួចរាល់នៅខែមេសា ឆ្នាំ២០២២ ដោយសាងសង់ពីបេតុងលើផ្ទៃដីជាង ៣ពាន់ម៉ែត្រក្រឡា មានបណ្តោយ ៦២ម៉ែត្រ ទទឹងជាង៥៧ម៉ែត្រ កម្ពស់២ជាន់ ដោយជាន់ទីមួយ មានចំនួន ២១០តូប

០៣







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ០២

## សម្តេចក្រឡាហោម សម្ពោធដាក់ឲ្យ...

ជាន់ទីពីរមាន២០០តូប រួមទាំងការបំពាក់ប្រព័ន្ធអគ្គិសនី ទឹកស្អាត ប្រព័ន្ធលូរំដោះទឹក និងការស្ថាបនាផ្លូវបេតុងភ្ជាប់ពីផ្សារទៅផ្លូវជាតិលេខ២៨ ប្រវែងជាង ៤០០ម៉ែត្រ ចំណាយថវិកាជាង១លាន៤សែន៧ម៉ឺនដុល្លារ និងមានការបំពាក់អំពូលភ្លើងបន្ថែមពីក្រុមការងាររាជរដ្ឋាភិបាលចុះជួយឃុំកំពង់ពពិល បន្ថែមទៀត ។

អញ្ជើញមានប្រសាសន៍សំណេះសំណាលនាឱកាសនោះ **សម្តេចក្រឡាហោម** បានបន្តគូសបញ្ជាក់ពីបុព្វហេតុ និងគុណតម្លៃនៃសន្តិភាព ព្រមទាំងបានថ្លែងអំណរគុណចំពោះក្រុមការងាររាជរដ្ឋាភិបាលចុះជួយស្រុកពារាំង និងគ្រប់ឃុំក្នុងស្រុកពារាំង ដែលបានរួមកម្លាំងសាមគ្គីគ្នាជាមួយអាជ្ញាធរស្រុក-ឃុំ និងប្រជាពលរដ្ឋគាំទ្រកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ធ្វើឱ្យសម្រេចបានសមិទ្ធផលជាបន្តបន្ទាប់ និងមានក្តីសង្ឃឹមថាបេសកកម្មនេះនឹងត្រូវបានអនុវត្តបន្ត ដើម្បីនាំមកនូវផលប្រយោជន៍ជូនប្រជាពលរដ្ឋ ។ ទន្ទឹមនេះសម្តេចក្រឡាហោមក៏បានសម្តែងនូវការសោកស្តាយជាមួយប្រជាពលរដ្ឋជាក្រុមអាជីវករផងដែរ ដែលបានខាតបង់តូប ទំនិញ និងទ្រព្យសម្បត្តិផ្សេងៗដោយសារគ្រោះអគ្គិភ័យកាលពីពេលកន្លងទៅនោះ។ ព្រមជាមួយនេះ **សម្តេច** ក៏បានថ្លែងអំណរគុណចំពោះបងប្អូនប្រជាពលរដ្ឋជាអាជីវករទាំងអស់ដែលបានអនុញ្ញាតជូន **សម្តេច** និងសហការីបានចូលរួមចំណែកសាងសង់ផ្សារថ្មីនេះទាំងស្រុង



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









ឡើងវិញ ព្រោះថា៖ « **បើពលរដ្ឋ មិនគាំទ្រ មិនឯកភាព ទោះបីជាយើងខ្ញុំចង់ យើងខ្ញុំមានធនធាន និងថវិកាយ៉ាងណាក៏ដោយ ក៏មិនអាចធ្វើផ្សារនេះបានដែរ** » ។

ពាក់ព័ន្ធនឹងដំណើរការសាងសង់ផ្សារនេះដែរ **សម្ដេចក្រឡាហោម** បានមានប្រសាសន៍ផ្ដល់ជូនបន្ថែមនូវការកែលម្អរផ្សារនេះដោយក្រាលកំរាលការ៉ូឱ្យបានស្អាតទាំងនៅផ្នែកជាន់ខាងក្រោម និងផ្នែកជាន់ខាងលើនៃផ្សារ ។ ជាមួយគ្នានេះសម្ដេចក៏បានស្នើសុំក្រុមអាជីវករទាំងអស់ឱ្យខិតខំបង្កើនការស្រុះស្រួលគ្នាជាមួយគណៈកម្មការផ្សារ និងអាជ្ញាធរដែនដីដើម្បីរៀបចំកន្លែងលក់ដូរទៅតាមប្រភេទនៃមុខទំនិញ រួមទាំងការការពារសន្តិសុខ និងសណ្ដាប់ធ្នាប់ឱ្យបានល្អ ។

**សម្ដេចក្រឡាហោម** ក៏បានជម្រាបជូនក្រុមអាជីវករដែរថា៖ ផ្សារកំពង់ពពិលដែលសាងសង់ក្នុងតម្លៃជាង១លានដុល្លារអាមេរិកនេះ មានការគាំទ្រពីសប្បុរសជនក្រុមការងារ និងសប្បុរសជនជាច្រើន ដែលការចំណាយសាងសង់នេះគឺមិនមានការតម្រូវឱ្យយកថវិកាពីពលរដ្ឋពេលវិលចូលមកលក់-ដូរវិញនោះឡើយ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សម្តេចក្រឡាហោម អនុញ្ញាតឲ្យលេខាធិការអចិន្ត្រៃយ៍ នៃសមាគមទីក្រុងប្រើប្រាស់ភាសាបារាំងចូលជួប សម្តែងការគួរសម និងពិភាក្សាការងារ



នារសៀលថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឱ្យ ឯកឧត្តម **ព្យែរ ប៉ៃយ៉េ** (Mr.PIERRE BAILLET) លេខាធិការ អចិន្ត្រៃយ៍នៃ សមាគមទីក្រុងប្រើប្រាស់ភាសាបារាំង (AIMF) និងសហការី ចូលជួបសម្តែងការ គួរសម និងពិភាក្សាការងារ ។

ក្នុងជំនួបនេះ សម្តេចក្រឡាហោម បានថ្លែងអំណរគុណ និងចូលរួមអបអរសាទរចំពោះទំនាក់ទំនងកិច្ចសហប្រតិ



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







បត្តិការរវាងទីក្រុងនិយាយភាសាបារាំងជាមួយសាលារាជធានីភ្នំពេញ ។ ក្នុងនោះ សម្តេចក្រឡាហោម ក៏បានសម្តែងនូវមនោសញ្ចេតនារីករាយស្វាគមន៍ចំពោះដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ មកកាន់ព្រះរាជាណាចក្រកម្ពុជា ស្របពេលដែលកម្ពុជា កំពុងតែដំណើរការឃុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ-សង្កាត់ ដែលទស្សនកិច្ចនេះ ក៏ជាការលើកទឹកចិត្តមួយបន្ថែមទៀតទៅដល់ទំនាក់ទំនងសហប្រតិបត្តិការរវាងកម្ពុជា-បារាំង ដែលជាប្រទេស មានទំនាក់ទំនងជាមួយគ្នាជាយូរណាស់មកហើយ។ មិនតែប៉ុណ្ណោះ ទស្សនកិច្ចនាពេលនេះក៏ជាការជំរុញទឹកចិត្តដល់យុវជនកម្ពុជាឱ្យបន្តចាប់យកការសិក្សាទៅលើភាសាបារាំងកាន់តែច្រើនឡើងថែមទៀត និងបានគាំទ្រចំពោះសមិទ្ធផលនានា ដែលកើតចេញពីកិច្ចសហប្រតិបត្តិការរវាងសាលារាជធានីភ្នំពេញជាមួយសមាគម AIMF ផងដែរ ។

ជាការឆ្លើយតប ឯកឧត្តម **ពៀរ ម៉ែយ៉េ** បានថ្លែងអំណរគុណចំពោះសម្តេចក្រឡាហោម និងគោរពជម្រាបជូន សម្តេច ថាឯកឧត្តម និងសហការីពិតជាមានសេចក្តីរីករាយចំពោះវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការរវាងសមាគមទីក្រុងនិយាយភាសាបារាំងជាមួយសាលារាជធានីភ្នំពេញ ដែលទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការនេះ មិនគ្រាន់តែផ្តោតសំខាន់ទៅលើការនិយាយភាសាបារាំងនៅទីក្រុងដែលជាសមាជិករបស់សមាគមប៉ុណ្ណោះទេ ប៉ុន្តែទំនាក់ទំនងកិច្ចសហប្រតិបត្តិការនេះក៏ផ្តោតទៅលើគោលបំណងនៃការអភិវឌ្ឍគាំទ្រដល់ការកសាងស្ពារហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការបង្កើតនូវអ្វីដែលហៅថា ថ្នាលបច្ចេកវិទ្យាបន្ថែមទៀត ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# អគារសិក្សា ១ខ្នង ១០បន្ទប់ នៅអនុវិទ្យាល័យ ខ្លាចរមាស ស្ថិតក្នុងស្រុកបវេល ខេត្តបាត់ដំបង ត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់





នៅព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយ ខេត្តបាត់ដំបង បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា១ខ្នង នៅអនុវិទ្យាល័យខ្លាចរមាស ស្ថិតនៅស្រុកបវេល ខេត្តបាត់ដំបង ។

លោក **លួត សាលី** អភិបាលនៃគណៈអភិបាលស្រុកបវេល ខេត្តបាត់ដំបង បានបញ្ជាក់ឱ្យដឹងថា៖ សាលាអនុវិទ្យាល័យខ្លាចរមាសកើតឡើងក្នុងឆ្នាំសិក្សា១៩៨៧ ដែលកាលនោះមានឈ្មោះថា **អនុវិទ្យាល័យខ្លាចរមាស** ហើយការកកើតសាលានេះ គឺតាមសំណូមពរស្នើសុំរបស់ប្រជាពលរដ្ឋ អាជ្ញាធរ



**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:04 AM



ផែនដី ដោយពួកគាត់សង្កេតឃើញថា សិស្សានុសិស្សដែលរស់នៅក្នុងឃុំខ្នាចរមាស ពួកគាត់បង្ខំចិត្តបោះបង់ការសិក្សា ដោយសារពុំមានលទ្ធភាពបញ្ជូនកូនឱ្យទៅរៀននៅអនុវិទ្យាល័យដែលនៅឆ្ងាយៗ និងម្យ៉ាងទៀតក៏ដោយសារមូលហេតុខ្វះថវិកា មធ្យោបាយធ្វើដំណើរ និងការស្នាក់នៅជាដើម ប៉ុន្តែក្រោយពីការបង្កើតអនុវិទ្យាល័យខ្នាចរមាស មានអគារសិក្សា ០១ខ្នង ០៧បន្ទប់ កសាងដោយសហគមន៍ឃុំខ្នាចរមាសតែនៅមានការខ្វះខាតគ្រូបង្រៀននិងអគារសិក្សាដដែល ។ ក្រោយមកនៅឆ្នាំ១៩៩៦ គណៈគ្រប់គ្រងសាលានិងសហគមន៍ ក៏បានស្នើសុំអគារសិក្សា ២ខ្នង ៦បន្ទប់ ដែលឧបត្ថម្ភឡើងដោយមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ។ លុះដល់ឆ្នាំ២០០២ ដោយសង្កេតឃើញការខ្វះខាតអគារសិក្សា សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារចុះជួយខេត្តបាត់ដំបង បានកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ។ លុះមកដល់ឆ្នាំ ២០១៩ ដោយមានការកើនឡើងសិស្សានុសិស្សជារៀងរាល់ឆ្នាំ ធ្វើឱ្យខ្វះខាតអគារសិក្សា សម្តេចក្រឡាហោម ក៏បានផ្តល់អគារថ្មី០១ខ្នង ២ជាន់ ១០បន្ទប់បន្ថែមទៀតក្នុងឆ្នាំសិក្សា២០១៩-២០២២ ដែល





០៩



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/bgot/ Page 11 of 68









តមកពីទំព័រ ០៨

**អគារសិក្សា ១ខ្នង ១០បន្ទប់ នៅអនុវិទ្យាល័យ.**

ត្រូវបានដាក់សម្ពោធឱ្យប្រើប្រាស់នាឱកាសដ៏ថ្លៃថ្លានេះ ដោយចំណាយថវិកាអស់ ៧៧០.000ដុល្លារអាមេរិក ។

អញ្ជើញមានប្រសាសន៍សំណេះសំណាលនាឱកាសនោះ **សម្តេចក្រឡាហោម** បានសង្កត់ធ្ងន់ រំលឹកពាក្យ **អរគុណសន្តិភាព** ដោយសម្តេចបានថ្លែងពន្យល់បន្ថែមថាមូលហេតុនៃការអរគុណសន្តិភាព គឺដោយសារទម្រាំមានសុខសន្តិភាពនេះ កម្ពុជាបានឆ្លងកាត់ការលំបាកច្រើនណាស់ ដូច្នេះកម្ពុជាត្រូវចងចាំ**ប្រវត្តិដ៏ជូរចត់ ការដណ្តើមបានសន្តិភាព ដោយលះបង់សាច់ស្រស់ ឈាមស្រស់ ការធ្វើពលិកម្មគ្រប់បែបយ៉ាងរបស់ប្រជាពលរដ្ឋ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីរាជការ និងរាជរដ្ឋាភិបាលនៃគណបក្សប្រជាជនកម្ពុជា** ដែលកើតចេញពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បន្ថែមថា៖ ការប្រារព្ធពិធី សម្ពោធអគារសិក្សានាឱកាសនេះ គឺបន្ទាប់ពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជាមានភាពធូរស្រាលឡើងវិញក្រោមការដឹកនាំនិងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ។ ហើយអគារសិក្សានេះ គឺជាសមិទ្ធផលចំណងដៃមួយទៀតជូនស្រុកបវេល ដែលសម្តេចមានសេចក្តីសង្ឃឹមជឿជាក់ថាវិស័យអប់រំក្នុងស្រុកមួយនេះ នឹងកាន់តែមានការរីកចំរើន ដើម្បីរួមចំណែកវិនិយោគបន្ថែមទៀតនូវធនធានមនុស្ស សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ហើយការបណ្តុះបណ្តាលធនធានមនុស្សនេះ គឺត្រូវការពេលច្រើនជាង១០ឆ្នាំ ទម្រាំធនធានមនុស្សនោះអាចចូលរួមបំរើជាតិ បំរើប្រជាពលរដ្ឋបាន ។

ក្នុងឱកាសនោះដែរ សម្តេចក្រឡាហោម ក៏បានផ្តល់អនុសាសន៍ ជូនមាតា



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





បិតាសិស្សឱ្យបន្តយកចិត្តទុកដាក់ថែរក្សា ថែទាំកូនឱ្យបានល្អ ពិសេសការអប់រំទូន្មានឱ្យកូនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ ដែលព្រមជាមួយនោះ លោកគ្រូ អ្នកគ្រូ ក៏ត្រូវខិតខំយកចិត្តទុកដាក់ដល់ការបង្រៀន និងអប់រំសិស្ស ទាំងចំណេះដឹង ចរិយា និងសុខភាព រួមទាំងថែទាំបរិស្ថានសាលាឱ្យបានស្អាតជាមួយនឹងការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព ។ ទន្ទឹមនេះអាជ្ញាធរភូមិ-ឃុំត្រូវបន្តរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពបង្កលក្ខណៈងាយស្រួល និងគាំទ្រដល់ដំណើរការបោះឆ្នោតប្រកបដោយសេរី និងស្មើភាព និងសូមអញ្ជើញបងប្អូនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត អញ្ជើញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ៕





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្តេចក្រឡាហោម ស្នើឲ្យក្រុមហ៊ុន ស៊ី ភី បច្ចេកទេសដល់មន្ត្រីកសិកម្ម និស្សិត សហគមន៍

នៅព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់រោងចក្រផលិតចំណីអាហាររបស់ក្រុមហ៊ុន **ស៊ី.ភី ខេមបូឌា ចំកាត់** ស្ថិតនៅឃុំដំបូវន្ត ស្រុកដុំគីរី ខេត្តកំពត ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ប៉ាន់យ៉ារ៉ាក់ ពូលថាប់** (Panyarak Poolthup) ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា។

ឯកឧត្តម **ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត បានអញ្ជើញថ្លែងរបាយការណ៍ស្វាគមន៍ ជូន**សម្តេចក្រឡាហោម** ព្រមទាំងអង្គពិធីអំពីស្ថានភាពទូទៅក្នុងខេត្តកំពត ពិសេសការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការបង្ការទប់







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# ខេមបូឌាចំកាត់ ជួយផ្សព្វផ្សាយ និងបណ្តុះបណ្តាល និងប្រជាកសិករអំពីបច្ចេកទេសថ្មីៗ

ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហាការនៅកម្ពុជា ។

ជាមួយគ្នានោះដែរ លោក **ឌុធ ថៃយ៉ាង គ្រៀងក្រៃវីជ** នាយករងក្រុមហ៊ុន **ស៊ី.ភី ខេមបូឌា ចំកាត់** ក៏បានបញ្ជាក់ឱ្យដឹងផងដែរថា៖ ក្រុមហ៊ុន **ស៊ី.ភី ខេមបូឌាចំកាត់** បានចាត់ទុកប្រទេសកម្ពុជា ជាគោលដៅអាទិភាពនៃការវិនិយោគ ហើយក្នុងរយៈពេល២៦ឆ្នាំនៃការវិនិយោគនៅកម្ពុជានោះ ក្រុមហ៊ុនមានអាជីវកម្មបីប្រភេទ រួមមាន អាជីវកម្មអាហារសត្វ ការចិញ្ចឹមសត្វ និងអាជីវកម្មអាហារកែច្នៃ និងបានទិញវត្ថុធាតុដើមមាននៅកម្ពុជាស្រាប់ ដូចជាពោត ដំឡូងមី និងចុងអង្ករជាដើម ។

១៣







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ១២

## សម្តេចក្រឡាហោម ស្នើឲ្យក្រុមហ៊ុន...

ឯកឧត្តម ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា ក៏បានគូសបញ្ជាក់ដែរថា៖ ចាប់តាំងពីឆ្នាំ១៩៩៦មក **ស៊ី.ធី ខេមបូឌា ចំភាត់** បានបោះទុនវិនិយោគជាបន្តបន្ទាប់នៅកម្ពុជា រហូតក្លាយជាក្រុមហ៊ុនចិញ្ចឹមសត្វ ផលិតចំណីសត្វ និងកែច្នៃអាហារដ៏មានសក្តានុពលមួយនៅកម្ពុជា ហើយនៅក្នុងអំឡុងពេលវិករាលដាលជំងឺកូវីដ-១៩នៅកម្ពុជាកន្លងមកនេះ ក្រុមហ៊ុន ក៏បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា យ៉ាងសកម្មក្នុងការប្រយុទ្ធនឹងជំងឺ ព្រមទាំងជួយសង្គ្រោះប្រជាជនផងដែរ ។

អញ្ជើញសំណេះសំណាលនាឱកាសនោះ **សម្តេចក្រឡាហោម នាយករដ្ឋមន្ត្រីស្តីទី** បានមានប្រសាសន៍គូសបញ្ជាក់ថា៖ ក្នុងនាម **សម្តេចតេជោ**ប្រមុខរាជរដ្ឋាភិបាល **សម្តេច**ពិតជាមានសេចក្តីរីករាយ ដែលបានអញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់រោងចក្រផលិតចំណីអាហាររបស់ក្រុមហ៊ុន **ស៊ី.ធី ខេមបូឌា ចំភាត់**នាឱកាសនេះ ។ ទន្ទឹមនេះ ក្នុងនាមជាតំណាងឱ្យ **សម្តេចតេជោ សម្តេច**ផ្ទាល់ ក៏មានសេចក្តីត្រេកអរផងដែរដែលបានចូលរួមផ្តល់កម្លាំងចិត្តទាំងកម្លាំងកាយសម្រាប់ក្រុមហ៊ុន**ស៊ី.ធី ខេមបូឌា ចំភាត់**និងសាកលវិទ្យាល័យ **ជាស៊ីម កំចាយមារ**ដែលមានកិច្ចសហប្រតិបត្តិការជាមួយគ្នា ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ថា៖ វិស័យកសិកម្មនៅកម្ពុជាបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនពិសេសចូលរួមចំណែក២០ភាគរយនៃផលិតផលក្នុងស្រុកសរុប ។ លើសពីនេះទៀតវិស័យកសិកម្ម កាន់តែដើរតួនាទីសំខាន់នៅក្នុងបរិបទនៃការប្រឈមមុខនឹងវិបត្តិកូវីដ-១៩ និងការប្រែប្រួលជារអវិជ្ជមានមួយចំនួនរបស់សាកលលោក ។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល








មិនតែប៉ុណ្ណោះវិស័យកសិកម្ម ក៏ជាកម្លាំងចលករជំរុញបដិវត្តន៍ឧស្សាហកម្មពិសេសកសិឧស្សាហកម្មសម្រាប់ទាំងពេលបច្ចុប្បន្ន និងអនាគត ដែលនាំមកនូវពហុប្រយោជន៍ និងគុណតម្លៃជាច្រើន ដូចជាការបន្ថែមតម្លៃ ការបង្កើនគុណភាព និងរយៈពេលនៃការរក្សាទុកផលិតផល ការពង្រីកទីផ្សារកសិផល ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការបង្កើតការងារក្នុងស្រុក កាត់បន្ថយចំណាកស្រុក និងបង្កើនឱកាសសម្រាប់ការនាំចេញផលិតផល ។

**សម្ដេចក្រឡាហោម** បានមានប្រសាសន៍ គូសបញ្ជាក់ថា៖ ការវិនិយោគរបស់ក្រុមហ៊ុន **ស៊ី.ភី ខេមបូឌា ចំកាត់** បង្កើតរោងចក្រកែច្នៃអាហារតាមស្តង់ដាអន្តរជាតិដែលសម្ពោធដាក់ឱ្យប្រើប្រាស់នាពេលនេះ គឺជាដំណោះស្រាយយុទ្ធសាស្ត្រ និងទាន់ពេលវេលាឆ្លើយតបទៅនឹងតម្រូវការផលិតកម្មសត្វ បង្កើតឱកាសការងារ កាត់បន្ថយការធ្វើចំណាកស្រុក បន្ថែមលើការពង្រីកសក្ដានុពលវិស័យកសិឧស្សាហកម្មនៅកម្ពុជា ដែលនេះបានបង្ហាញនូវសុទិដ្ឋិនិយមខ្ពស់ចំពោះដំណើរការរបស់ក្រុមហ៊ុន **ស៊ី.ភី ខេមបូឌា ចំកាត់** ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាម **សម្ដេចតេជោ ហ៊ុន សែន សម្ដេចក្រឡាហោម** បានសំដែងនូវការគាំទ្រ និងលើកទឹកចិត្តក្រុមហ៊ុនឱ្យបន្តវិនិយោគសាងរោងចក្រផលិតចំណីអាហារបែបនេះបន្ថែមទៀត នៅតាមបណ្ដាខេត្តដែលមានសក្ដានុពលនៅកម្ពុជា ហើយទន្ទឹមគ្នានេះ **សម្ដេច** ក៏បានស្នើឱ្យក្រុមហ៊ុន **ស៊ី.ភី ខេមបូឌាចំកាត់** ជួយផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលបច្ចេកទេសដល់មន្ត្រីកសិកម្ម និស្សិត សហគមន៍ និងប្រជាកសិករអំពីបច្ចេកទេសថ្មីៗផងដែរ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត
## ជាមួយអនុរដ្ឋមន្ត្រី



នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានអញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់ក្រសួងនគរបាលវៀតណាម ដឹកនាំដោយឯកឧត្តម ឧត្តមសេនីយ៍ឯកបម្រុង **លឿង តាមក្វាង** អនុរដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម ។








៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# នេត សាវឿន ទទួលជួបពិភាក្សាការងារ ក្រសួងនគរបាលវៀតណាម



ក្នុងកិច្ចប្រជុំនេះភាគីទាំងពីរបាន ឯកភាពគ្នាបន្តពង្រឹងកិច្ចសហប្រតិបត្តិលើចំណុចសំខាន់ៗចំនួន៥ ដែលមានជាអាទិ៍៖

**ទី១**-កងកម្លាំងមានសមត្ថកិច្ចនៃប្រទេសទាំងពីរត្រូវបន្តពង្រឹងការផ្លាស់ប្តូរព័ត៌មានសន្តិសុខ ដើម្បីការពារខឿនសន្តិសុខជាតិនៃប្រទេសនិមួយៗ និងក្នុងតំបន់ ពិសេសរក្សាសាមគ្គីភាព និងទំនាក់ទំនងសហប្រតិបត្តិការនៃប្រទេសវៀតណាម និងកម្ពុជា។

**ទី២**-ភាគីទាំងពីរពង្រឹងកិច្ចសហការធានារក្សាសន្តិសុខ សុវត្ថិភាពសម្រាប់ព្រឹត្តិការណ៍នយោបាយសំខាន់ៗរបស់ប្រទេសនីមួយៗឲ្យបានជោគជ័យ ពិសេសព្រឹត្តិការណ៍ខួបនៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរថ្ងៃ២៤ មិថុនា ឆ្នាំ១៩៦៧-២០២២ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រសួង ។ ក្រសួងនគរបាលវៀតណាម ត្រៀមជាស្រេចក្នុងការចែករំលែក

១៧



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា






**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន**
**អគ្គស្នងការ នគរបាលជាតិ**

**ឯកឧត្តម ឧត្តមសេនីយ៍ឯកបម្រុង លឿង តាមក្វាង អនុរដ្ឋមន្ត្រី**
**ក្រសួងនគរបាលវៀតណាម**







តមកពីទំព័រ ១៦

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត...**

បទពិសោធន៍ និងសហការជាមួយក្រសួងមហាផ្ទៃកម្ពុជា ក្នុងការជួយរៀបចំសន្តិសុខសណ្តាប់ធ្នាប់ ក្នុងព្រឹត្តការណ៍តំបន់ និងនយោបាយធំៗដែលកម្ពុជាត្រៀមរៀបចំនៅពេលខាងមុខនេះ រួមមាន៖ កិច្ចប្រជុំកំពូលអាស៊ាន ការត្រៀមរៀបចំបោះឆ្នោតតំណាងរាស្ត្រនៅឆ្នាំ២០២៣ ការប្រកួតកីឡាស៊ីហ្គេម ជាដើម ។

**ទី៣**-ភាគីទាំងពីរត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពចំពោះខ្លឹមសារទាំងអស់ដែលបានឯកភាពនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីរវាងប្រទេសកម្ពុជា-វៀតណាម-ឡាវ ស្តីពីការពង្រឹងកិច្ចសហការបង្ការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេសបទល្មើសគ្រឿងញៀន បទល្មើសជួញដូរមនុស្សក្នុងនោះស្នើសុំអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា សហការជាមួយក្រសួងនគរបាលវៀតណាម បង្ការ បង្ក្រាបទប់ស្កាត់ឈ្មួញឆបោក ដែលរៀបចំឲ្យប្រជាពលរដ្ឋវៀតណាមឆ្លងដែនចូលកម្ពុជាដោយខុសច្បាប់ ទន្ទឹមនោះក៏សូមថ្លែងអំណរគុណដល់នគរបាលកម្ពុជា ដែលបានជួយសង្គ្រោះឲ្យជនរងគ្រោះជនជាតិវៀតណាមបានត្រឡប់ទៅផ្ទះសម្បែងវិញផងដែរ ។

**ទី៤**-ភាគីទាំងពីរបន្តពិភាក្សាស្វែងរកដំណោះស្រាយជាស្ថាពរនៅចំណុចបន្ទាត់ព្រំដែន ដែលនៅសេសសល់តាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដើម្បីបញ្ចប់ការងារបោះបង្គោលព្រំដែនឲ្យបានឆាប់ ណែនាំឲ្យស្ថាប័នមានសមត្ថកិច្ចនៅតាមមូលដ្ឋានសហការដោះស្រាយបញ្ហាដែលកើតមានឡើងនៅតាមព្រំដែន ធានាសន្តិសុខខ្សែបន្ទាត់ព្រំដែនរួមចំណែកកសាងខ្សែបន្ទាត់ព្រំដែនសន្តិភាព និង



**ពានរបារ** ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល











អភិវឌ្ឍតាមស្មារតីក្នុងជំនួបរវាងនាយករដ្ឋមន្ត្រីប្រទេសទាំងពីរ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ។

**ទី៥**-ក្រសួងនគរបាលវៀតណាម សូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់គាំទ្រអនិកជនជនជាតិវៀតណាមនៅកម្ពុជា ជាពិសេសជួយយកចិត្តទុកដាក់ដោះស្រាយបញ្ហាដល់អនិកជនវៀតណាម ។

ក្នុងជំនួបនេះដែរ ឯកឧត្តម ឧត្តមសេនីយ៍ឯកបម្រុង **លឿង តាមក្វាង** អនុរដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម ក៏បានអញ្ជើញ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ទៅបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋសង្គមនិយមវៀតណាម នៅពេលសមស្របណាមួយផងដែរ ។

ជាការឆ្លើយតប ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានទទួលយកការអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសវៀតណាម និងថ្លែងអំណរគុណ ក៏ដូចជាគាំទ្រចំពោះកិច្ចការដែលនាំមកនូវចំណងសាមគ្គីភាព មិត្តភាព រវាងនគរបាលវៀតណាម និងក្រសួងមហាផ្ទៃ ក៏ដូចជាអគ្គស្នងការដ្ឋាននគរបាលជាតិ នាពេលកន្លងមក ។

**គួរបញ្ជាក់ផងដែរថា**៖ ក្រោយបញ្ចប់ជំនួបពិភាក្សាការងារ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានអញ្ជើញទទួលសម្ភារជំនួយរបស់ក្រសួងនគរបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជូនក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី កាលពីឆ្នាំ២០២០ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# វេទិកាអុំទូក និង សំណង់សិល្បការផ្សេងៗ

## ខេត្តព្រះវិហារ ត្រូវបាន




ឯកឧត្តម ប្រាក់ សុវណ្ណ អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ



កាលពីព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការវេទិកាអុំទូកនិងសំណង់សិល្បការផ្សេងៗ ស្ថិតក្នុងភូមិកំពង់ស្រឡៅ ឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ ។

នៅក្នុងរបាយការណ៍ស្វាគមន៍របស់ ឯកឧត្តម **ប្រាក់ សុវណ្ណ** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ បានបញ្ជាក់ថា៖ ឃុំកំពង់ស្រឡៅមួយ មានផ្ទៃដី ចំនួន ៦២២,១៩គីឡូម៉ែត្រក្រឡា ប្រជាពលរដ្ឋចំនួន ៨០៥គ្រួសារ ស្មើនឹងចំនួនមនុស្ស៣.៦៣០នាក់/ស្រី១.៨២៣នាក់ មាន ៥ភូមិ មានព្រំប្រទល់ជាប់ជាមួយស្រុក ម៉ុនឡាប៉ាម៉ុក និងស្រុកខ្វង



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ស្ថិតក្នុងភូមិកំពង់ស្រឡៅ ស្រុកឆែប សម្ពោធដាក់ឲ្យប្រើប្រាស់





ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ។ ជារួមការទំនាក់ទំនងនៅតំបន់នេះមានលក្ខណៈជាច្រកប្រពៃណីដោយមានការផ្លាស់ប្តូរទំនិញផ្សេងៗជាលក្ខណៈគ្រួសារ និងឆ្លងសុំសេវាព្យាបាលសុខភាព និងដោយឡែកសម្រាប់ខេត្តទាំងពីរព្រះវិហារ-ចម្ប៉ាសាក់គឺមានកិច្ចប្រជុំប្រចាំឆ្នាំដោយផ្លាស់ប្តូរវេនគ្នាធ្វើជាម្ចាស់ផ្ទះ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខសណ្តាប់ធ្នាប់ និងសេដ្ឋកិច្ច សង្គមកិច្ច ដោយផ្អែកលើមូលដ្ឋានកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជានិងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ ក្រៅពីនេះខេត្តព្រះវិហារ-ចម្ប៉ាសាក់ និងស្រុកឆែប-ស្រុកខូងតែងតែរៀបចំពិធី ពិព័ណ៌វប្បធម៌ ការប្រកួតកីឡា និងប្រណាំងទូក

២១







តមកពីទំព័រ ២០

## វេទិកាអុំទូក និងសំណង់សិល្បការ ...

មិត្តភាពរួមគ្នាប្រចាំឆ្នាំដោយផ្លាស់ប្តូរវេនគ្នាធ្វើជាម្ចាស់ផ្ទះចាប់ពីឆ្នាំ២០១៤ និងជាបន្តបន្ទាប់មកទៀតបានឯកភាពគ្នារៀបចំក្នុងរយៈពេល ០២ឆ្នាំម្តងវិញ ។ ប៉ុន្តែទាំងកិច្ចប្រជុំ និងពិធីនេះត្រូវបានខកខានប្រារព្ធធ្វើចាប់ពីឆ្នាំ២០១៩មក ដោយបញ្ហាជំងឺកូវីដ-១៩ ហើយឆាប់ៗខាងមុខនេះ ខេត្តព្រះវិហារ និងខេត្តចម្ប៉ាសាក់ នឹងរៀបចំកិច្ចប្រជុំលើកទី០៩ស្តីពី កិច្ចសហប្រតិបត្តិការបន្ត ដោយភាគីខេត្តចម្ប៉ាសាក់ជាម្ចាស់ផ្ទះ ។

ផ្តើមចេញពីកិច្ចសហប្រតិបត្តិការខាងលើ និងដោយមើលឃើញសំណង់វេទិការអុំទូកមានសភាពចាស់ទ្រុឌទ្រោមចាំបាច់ត្រូវសាងសង់ថ្មី ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រដ៏ខ្លង់ខ្លស់ពីសំណាក់សម្តេចក្រឡាហោម **ស ខេង** និងលោកជំទាវ **ញ៉ែម សាខន ស ខេង** ទើបយើងទទួលបានវេទិកាថ្មី និងសំណង់សិល្បការនានាដូចពេលនេះ ។

អញ្ជើញសំណេះសំណាលក្នុងពិធីនោះសម្តេចក្រឡាហោម បានមានប្រសាសន៍អរគុណចំពោះខេត្តចម្ប៉ាសាក់ក៏ដូចជារដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលតែងតែកម្ពុល់នូវកិច្ចសហប្រតិបត្តិការល្អ ជាមួយនិងព្រះរាជាណាចក្រកម្ពុជា ហើយជាពិសេសខេត្តដែលជាប់ព្រំដែនកម្ពុជា គឺតែងតែយកចិត្តទុកដាក់ ដើម្បីទំនាក់ទំនងសហប្រតិបត្តិការជួបគ្នា ដើម្បីដោះស្រាយបញ្ហានានាដែលកើតឡើងនៅតាមព្រំដែនស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជារដ្ឋាភិបាលឡាវ និងគោលការណ៍របស់ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ ។

ដោយឡែកពាក់ព័ន្ធនិងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ **សម្តេចក្រឡាហោម** បានមានប្រសាសន៍សង្កត់ធ្ងន់ថា៖ យើងចាត់ទុកថាការបោះឆ្នោតឃុំ-សង្កាត់ដែលនិងខិតជិតមកដល់នៅពេលឆាប់ៗនេះ គឺជាការបោះឆ្នោតដែលមានសារៈសំខាន់មួយជាយុទ្ធ



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







សាស្ត្រក្រុងបំណាង ដើម្បីបន្តពង្រឹងលទ្ធិប្រជាធិបតេយ្យនៅហ្នឹងមូលដ្ឋានឱ្យកាន់តែរឹងមាំថែមទៀត ដែលជាការបង្កឱកាសជូនប្រជាពលរដ្ឋដែលជាម្ចាស់ទឹកម្ចាស់ដីលោកមានសិទ្ធិគ្រប់គ្រាន់ដើម្បីនិងបោះឆ្នោតជ្រើសរើសអ្នកដឹកនាំរបស់ខ្លួននៅហ្នឹងមូលដ្ឋានព្រោះយើងទាំងអស់គ្នាដឹងហើយថាពីមុននេះអ្នកដឹកនាំនៅមូលដ្ឋានឃុំ-សង្កាត់នេះ គឺកើតឡើងដោយសារការចាត់តាំង ការចង្អុលជ្រើសរើសតាមឋានានុក្រម ថ្នាក់ស្រុក ឬថ្នាក់ខេត្ត ប៉ុន្តែយើងបានបោះបង់ចោលហើយនូវរបៀបជ្រើសតាំងបែបនេះ ។ ដោយមានការគាំទ្រពីរដ្ឋាភិបាល តាមរយៈការផ្ទេរធនធាន ទាំងធនធានថវិកា ធនធានទ្រព្យសម្បត្តិផ្សេងទៀតក៏ដូចជាធនធានមនុស្សមកក្រុមប្រឹក្សាឃុំ-សង្កាត់គាត់ប្រើប្រាស់ធនធាននេះ ដើម្បីគាត់ចាត់ចែងកិច្ចការងារនៅហ្នឹងមូលដ្ឋានរបស់គាត់ អភិវឌ្ឍសេដ្ឋកិច្ចជីវភាពរស់នៅ ជូនប្រជាពលរដ្ឋដែលធ្វើឱ្យប្រជាពលរដ្ឋលោកមានឱកាសពេញទី ដើម្បីចូលរួមយោបល់ទៅលើការចាត់ចែងកិច្ចការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលគាត់បានជ្រើសតាំង ហើយមានការពាក់ព័ន្ធ និងផលប្រយោជន៍នៅក្នុងឃុំ-សង្កាត់ ។

គួរបញ្ជាក់ដែរថា៖ សមិទ្ធផលដែលដាក់សម្ពោធឱ្យប្រើប្រាស់នាពេលនេះមាន ៖

**១-វេទិកាអុំទូក** មានទំហំបណ្តោយ ២៧ម៉ែត្រ ទទឹង១៥ម៉ែត្រ កម្ពស់១៦,៣៣ម៉ែត្រ និងប្រកក្បឿង ចំណាយថវិកា អស់ ៦០០លានរៀល ។

**២-ច្រាំងទន្លេសងខាងវេទិកា** មានប្រវែង១១០ម៉ែត្រ និងជម្រៅ ១៨ម៉ែត្រ ចំណាយថវិកា ៨៧៤លានរៀល ។

**៣-របងស៊ីម៉ងត៍ក្លោងទ្វារ** ក្រាលក្រានីត និងសួនច្បារ ចំណាយថវិកាអស់៥២០លានរៀល ។

**៤-អគារស្នាក់នៅ** មានទំហំបណ្តោយ ១៩ម៉ែត្រ ទទឹង០៦ម៉ែត្រ មានបន្ទប់ស្នាក់នៅ ០២បន្ទប់ ឃ្លាំង ០១បន្ទប់ និងបន្ទប់ទឹកបុរស ស្ត្រី ចំណាយថវិកាអស់ ២០៦លានរៀល ។

**៥-រោងទូក** មានទំហំបណ្តោយ ២៥ម៉ែត្រ ទទឹង០៦ម៉ែត្រ និងប្រក់ក្បឿង ចំណាយថវិកាអស់ ១៦៥លានរៀល ។

**៦-អាគ្រមបួងសួងនៅខាងឆ្វេងវេទិកា** មានទំហំបណ្តោយ ០៥ម៉ែត្រ ទទឹង ២,៧ម៉ែត្រ និងតម្កល់រូបសំណាក់លោកយាយទេព ចំណាយថវិកាអស់ ៨០លានរៀល ។

៧-អាគ្រមបួងសួងនៅខាងស្តាំវេទិកា មានទំហំបណ្តោយ ០៥ម៉ែត្រ ទទឹង២,៧ម៉ែត្រ និងតម្កល់រូបសំណាក់លោកតាក្រហមក ចំណាយថវិកាអស់ ៨០លានរៀល ។

**៨-រូបសំណាក** ចំនួន០៥ ចំណាយថវិកាអស់ ៥១លានរៀល ។

**៩-ការរៀបចំតុបតែងលម្អផ្សេងៗ** ចំណាយថវិកាអស់ ២៧លានរៀល ។

សរុបការចំណាយខាងលើចំនួន ២.៦០៣ (ពីរពាន់ប្រាំមួយរយបីលានរៀល) ។

ក្រៅពីសមិទ្ធផលនេះ ក៏មានផ្លូវក្រាលកៅស៊ូប្រភេទ ឌីប៊ីអេសធី (DBST) ប្រវែង ២.៥០០ម៉ែត្រ ចំណាយថវិកាអស់ ៥.០០០.០០០.០០០៛ (ប្រាំប៊ីលានរៀល) ប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល ដែលចាប់ផ្តើមសាងសង់នៅចុងខែមីនា ឆ្នាំ២០២២ ដោយជំរុញការសាងសង់មុនគេត្រង់ចំណុចវេទិកានេះ នឹងបញ្ចប់ជាស្ថាពរក្នុងខែមិថុនា ឆ្នាំ២០២២ នេះ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# សម្ដេចក្រឡាហោម « នោះយើងមានកម្លាំងបានល្អដែរ បើគ្មានការគាំទ្រ

សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលបឋមវិជ្ជាជីវៈនគរបាលជំនាន់ទី១៥ លើកទី១ នៅសាលានគរបាលជាតិភូមិភាគ៦ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្ដម រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ព្រមទាំងថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធជាច្រើនរូបទៀត ។

នៅក្នុងរបាយការណ៍ស្វាគមន៍របស់ ឯកឧត្ដម នាយឧត្ដមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន** អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងជាប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល បានបញ្ជាក់ថា៖ ចាប់តាំងពីពេលបង្កើតរហូតមកដល់ពេល



ឯកឧត្ដម នាយឧត្ដមសេនីយ៍ សាស្ត្រាចារ្យ ឯក មនោសែន អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា





ពការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ប៉ុន្មានក៏ដោយ ក៏មិនអាចរក្សាសន្តិសុខសណ្ដាប់ធ្នាប់ និង ការចូលរួមពីប្រជាពលរដ្ឋ »





នេះសាលានគរបាលជាតិភូមិភាគ៦ បានបណ្ដុះបណ្ដាលសិស្សនគរបាលចំនួន ៦១១៧នាក់ នារី ៤៦៣នាក់ និងជាមធ្យមបណ្ដុះបណ្ដាលបាន ៥០០នាក់ ក្នុងមួយឆ្នាំ ។ ដោយឡែកនៅក្នុងឆ្នាំ២០២២នេះ សាលានគរបាលជាតិភូមិភាគ៦ បានបណ្ដុះបណ្ដាលសិស្សនគរបាលជំនាន់ទី១៥ លើកទី១ ចំនួន១៨០នាក់ នារី ២១នាក់ ជាសិស្សនគរបាលមកពីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដែលប្រឡងជាប់ក្នុងក្របខណ្ឌឆ្នាំ២០២០ និងស្ថិតក្នុងចំណោមសិស្សនគរបាលសរុប ១១០៨នាក់ ដែលបានបណ្ដុះបណ្ដាលនៅសាលានគរបាលភូមិភាគទាំង៦ ។

អញ្ជើញមានប្រសាសន៍សំណេះសំណាលនាឱកាសនោះ **សម្ដេចក្រឡាហោម** បានសម្ដែងនូវការកោតសរសើរ

២៥



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ២៤

**សម្តេចក្រឡាហោម នោះយើងមានកម្លាំង...**

ចំពោះបណ្ឌិត្យសភានគរបាលកម្ពុជា ដែលបានខិតខំប្រឹងប្រែងចាត់ចែងការងារបណ្តុះបណ្តាលធនធានមនុស្សផ្នែកនគរបាលជាតិទទួលបានលទ្ធផលជាបន្តបន្ទាប់ ។ សម្តេចក៏បានថ្លែងអំណរគុណ និងកោតសរសើរចំពោះសាស្ត្រាចារ្យ និងគ្រូនគរបាលជាតិទាំងអស់ដែលបានខិតខំពង្រឹងការបណ្តុះបណ្តាលសិស្សនគរបាលឱ្យមានចំណេះដឹង និងសមត្ថភាពក្នុងវិជ្ជាជីវៈ។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានថ្លែងអំណរគុណចំពោះរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខេត្តកណ្តាល និងរដ្ឋបាលខេត្តកំពង់ឆ្នាំង ដែលបានចូលរួមគាំទ្រការអភិវឌ្ឍសាលានគរបាលភូមិភាគ៦ ខេត្តកំពង់ឆ្នាំងនេះទៅតាមលទ្ធភាព និងតម្រូវការជាក់ស្តែងនៅថ្ងៃនេះដែលមាន ដូចជារដ្ឋបាលរាជធានីភ្នំពេញ បានផ្តល់អគារស្នាក់នៅមួយខ្នង រដ្ឋបាលខេត្តកំពង់ឆ្នាំងបានសម្រេចផ្តល់ផ្លូវក្រាលកៅស៊ូចូលសាលា និងខេត្តកណ្តាលជួយអគារ១ខ្នង សម្រាប់ការសិក្សា និងការងាររដ្ឋបាល ។

ពាក់ព័ន្ធនឹងសំណើរសាងសង់អាហារដ្ឋាន និងទីលានហ្វឹកហាត់នៅសាលានគរបាលភូមិភាគ៦នេះ **សម្តេចក្រឡាហោម** បានឯកភាពទទួលដោះស្រាយតាមសំណូមពរ និងបានស្នើដល់មន្ត្រីពាក់ព័ន្ធរៀបចំការសិក្សាគម្រោង និងប្លង់ឱ្យបានលម្អិតដែលក្នុងនោះ **សម្តេច** ក៏បានឯកភាពចំពោះសំណើរបំពេញចំនួនក្របខណ្ឌនគរបាលផងដែរដោយបញ្ហានេះ **សម្តេច**មានប្រសាសន៍បញ្ជាក់ថា៖ ការផ្តល់ជូននេះគឺដើម្បីសម្រួលដល់ការបំពេញបេសកកម្មរបស់បណ្តុះបណ្តាលនគរបាលជាតិឱ្យក្លាយជាមន្ត្រីប្រកបដោយសមត្ថភាពវិជ្ជាជីវៈក្នុងការងារបំរើជាតិ និងប្រជាជន ។

**សម្តេចក្រឡាហោម** មានប្រសាសន៍សង្កត់ធ្ងន់ថា « **នគរបាលយើងត្រូវតែមាន សមត្ថភាព វិជ្ជាជីវៈ មានសីលធម៌ល្អ** ដូចដែលក្មួយៗ ប្អូនៗបានសិក្សានេះ គឺនោះហើយជាចំណេះវិជ្ជា ចំណេះដឹងដែលយើងត្រូវប្រកាន់ខ្ជាប់ពេលយើងបំពេញបេសកកម្ម ដើម្បីប្រែក្លាយខ្លួនយើងជាមន្ត្រីនគរបាលរបស់ប្រជាពលរដ្ឋ ពលរដ្ឋមិនខ្លាចញញើតយើង ពលរដ្ឋគាត់ស្រលាញ់ ជឿទុកចិត្ត និងផ្តល់កិច្ចសហការជាមួយយើង ។ **ហើយទោះបីយើងមានកម្លាំងប៉ុន្មានក៏ដោយ ក៏មិន**



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







**អាចរក្សាសន្តិសុខសណ្តាប់ធ្នាប់បានល្អនោះ បើគ្មានការគាំទ្រ និងការចូលរួមពីប្រជាពលរដ្ឋ...** នេះជាគោលការណ៍ និងជាទ្រឹស្តីត្រូវចងចាំ »។

លើសពីនេះទៀត **សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍ពន្យល់ជូនអង្គពិធីអំពីទស្សនៈពាក់ព័ន្ធនឹងនគរបាលជាតិរួមមាន៖ **ទី១បញ្ចូល៖** សំដៅលើការបញ្ចូលក្របខណ្ឌនគរបាលដោយឆ្លងកាត់ការប្រឡងប្រជែង ។ **ទី២បណ្តុះ៖** សំដៅដល់ការបង្រៀនឱ្យចេះទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ។ **ទី៣បណ្តាល៖** សំដៅលើការតែងតាំងឱ្យបំពេញការងារតាមជំនាញ និងផ្នែក បន្ទាប់ពីបានបង្រៀនឱ្យចេះ ។ **ទី៤បណ្តារ៖** សំដៅដល់ការលើកទឹកចិត្ត ដូចជាការតម្លើងស័ក្តិ ឋានៈ តួនាទី រង្វាន់ និងបណ្ណសរសើរជាដើម ។ **ទី៥បណ្ដ្យរ៖** គឺសំដៅលើវិធានការចំពោះមន្ត្រីមានកំហុស ដូចជា ការស្តីបន្ទោស និងដាក់វិន័យជាដើម ។ **ទី៦បញ្ចេញ៖** សំដៅដល់ការដកក្របខណ្ឌចេញពីនគរបាល បើកាលណាមានកំហុសធ្ងន់ធ្ងរ ដូចជា ប្រព្រឹត្តបទល្មើស និង**ទី៧បញ្ចប់៖** សំដៅដល់ការរៀបចំចូលនិវត្តន៍ ឬការបាត់បង់កាយសម្បទាវិជ្ជាជីវៈជាដើម ។

សំខាន់ជាងនេះទៀត **សម្តេចក្រឡាហោម** ក៏បានណែនាំឱ្យបណ្ឌិត្យសភានគរបាលកម្ពុជា ខិតខំបន្តសិក្សាស្រាវជ្រាវដើម្បីផ្តួចផ្តើមគំនិតច្នៃប្រឌិតថ្មីៗ បន្ថែមទៀតក្នុងការដឹកនាំគ្រប់គ្រង និងអនុវត្តកំណែទម្រង់នគរបាលជាតិតាមផែនការជាពិសេសខិតខំតាមដានស្រាវជ្រាវចំពោះបទល្មើសថ្មីៗដែលបានកើតឡើងក្នុងប្រទេស តំបន់ និងសាកលលោក ដើម្បីឱ្យបានដឹង និងដកពិសោធន៍ធ្វើជាមេរៀនបង្រៀនដល់សិក្ខាកាម និងសិស្សនគរបាលទាំងទ្រឹស្តី និងការអនុវត្ត ព្រមទាំងបន្តការសហការបណ្តុះបណ្តាលមន្ត្រីនគរបាលក្របខណ្ឌថ្មី មន្ត្រីនគរបាលនៅមិនទាន់បានរៀន និងមន្ត្រីផ្ទេរក្របខណ្ឌចូលនគរបាលជាតិ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្តេចក្រឡាហោម អញ្ជើញពិនិត្យវឌ្ឍនភាព

កាលពីរសៀលថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញត្រួតពិនិត្យដំណើរការសាងសង់អគារទីស្តីការថ្មីក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ព្រមទាំងអង្គភាពពាក់ព័ន្ធជាច្រើនរូបទៀត ។

ឧត្តមសេនីយ៍ឯក **ប៊ិន មណីរដ្ឋ** ប្រធាននាយកដ្ឋានស្ថាបនា និងវិស្វកម្ម នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ បានបញ្ជាក់ប្រាប់ **ទស្សនាវដ្តីមិត្តនគរបាល** ឱ្យដឹងថា៖ គិតមកដល់ថ្ងៃនេះដំណើរការសាងសង់សម្រេចបានលទ្ធផលសរុបជារួម ៣៦%ធៀបនឹងកិច្ចសន្យា ដោយគ្រឿង

២៩







៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# នៃដំណើរការសាងសង់អគារទីស្តីការថ្មី ក្រសួងមហាផ្ទៃ











៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



តមកពីទំព័រ ២៧

## សម្តេចក្រឡាហោម អញ្ជើញពិនិត្យ...

បន្ទុំសំណង់ផ្ទៃក្រឡាចាក់បេតុងប្លង់សេកប្រមាណរួចចំនួន ៥៤.៤៣៤ម២ ស្មើនឹង ៥១% នៃផ្ទៃក្រឡាសរុប ១០៥.៥៤៥ម២ កើនឡើង ១៧.៣៤៤ម២ ធៀបនឹងខែមុន ។ ប្លង់សេជាន់ទី៣ បានចាក់រួចរាល់ចំនួន ៧.៧៦០ម២ នៅសល់តែប្លុកទី២ ទំហំ ១.៧០១ម២ ដែលបច្ចុប្បន្នកំពុងដំណើរការការងារតម្លើងពុម្ពប្លង់សេ ។ តាមប្រតិទិនការងារត្រឹមជាន់ទី៤ ទំហំ៥៧.៥៩២ម២ ត្រូវបញ្ចប់ការងារចាក់ប្លង់សេនៅដើមខែមិថុនា ឆ្នាំ២០២២នេះ ។

ដោយឡែកទិសដៅការងារបន្តចំពោះមុខនេះយើង និងជំរុញបញ្ចប់ការងារមួយចំនួនទៀតដូចជា៖

-ការងារចាក់បេតុងប្លង់សេជាន់ទី៣ និងទី៤ ក្នុង ខែមិថុនា ឆ្នាំ២០២២

-បន្តការងារបេតុងជាន់ទី៥ និងទី៦

-ការងារបិទការ៉ូជញ្ជាំងបន្ទប់ទឹកជាន់ចំណតរថយន្ត(គំរូ)

-ការងារតម្លើងជ្រីនៅជាន់ចំណតរថយន្ត និងជាន់ផ្ទាល់ដី

-ការងារជញ្ជាំងឥដ្ឋខាងក្រៅ និងខាងក្នុងអគារ នៅជាន់ផ្ទាល់ដី និងជាន់ទី១ និងបញ្ចប់ការងាររៀបចំបណ្តាញអគ្គិភ័យនៅជាន់ចំណតរថយន្ត ៕









៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

















៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន
## និងក្រុមកីឡាករបាល់ទះកម្ពុជា ដែលទើបវិលត្រឡប់ពីការ



ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងជាប្រធានសហព័ន្ធកីឡាបាល់ទះកម្ពុជា

នាព្រឹកថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ កន្លងមកនេះ នៅមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងជាប្រធានសហព័ន្ធកីឡាបាល់ទះកម្ពុជា បាន អញ្ជើញជួបសំណេះសំណាលជាមួយ ប្រតិភូគ្រូបង្វឹក និងក្រុមកីឡាករបាល់ទះកម្ពុជា ដែលទើបទទួលបានមេដាយសំរិទ្ធ ជាប្រវត្តិ









៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

# អញ្ជើញជួបសំណេះសំណាលជាមួយប្រតិភូ គ្រូបង្វឹក ប្រកួតកីឡា ស៊ីហ្គេមលើកទី៣១ នៅប្រទេសវៀតណាម







សាស្ត្រ ក្នុងព្រឹត្តិការណ៍កីឡាស៊ីហ្គេម (Sea Game) លើកទី៣១ ឆ្នាំ២០២២ នៅរដ្ឋធានីហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ។

មានប្រសាសន៍សំណេះសំណាល ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ និងជាប្រធានសហព័ន្ធកីឡាបាល់ទះកម្ពុជា បានសម្តែងនូវការអបអរសាទរចំពោះជ័យជំនះដែលក្រុមប្រតិភូក៏ដូចជាគ្រូបង្វឹកនិងក្រុមកីឡាករបាល់ទះជម្រើសជាតិកម្ពុជា ទាំងអស់ដែលដណ្តើមបានស្នាដៃយ៉ាងល្អ ជូនប្រទេសជាតិ ដែលយើងទាំងអស់គ្នាត្រូវតែមានមោទនភាពចំពោះអ្វីដែលយើងទទួលបាននៅពេលនេះ ហើយត្រូវចាត់ទុកជាជោគជ័យដ៏ធំក្នុងជំហានទី១ ដែលវិស័យកីឡាបាល់ទះរបស់យើងប្រហែល៤០ឆ្នាំកន្លងមកនេះមិនដែលទទួលបានជោគជ័យដូចពេលនេះទេ ។

ក្នុងពិធីសំណេះសំណាលនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ និងជាប្រធានសហព័ន្ធកីឡាបាល់ទះកម្ពុជា បានមាន

៤២



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ប្រធាន គ.ស.ហ ស្នើតំណាងអង្គទូត និងដៃគូរអភិវឌ្ឍន៍
## ទាំងអស់បន្តផ្តល់កិច្ចសហការ និងគាំទ្របន្ថែមទៀតដល់ ប្រទេសកម្ពុជា ចំនួន ២ចំណុច



ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាអនុប្រធាន (គ.ស.ហា)

កាលពីព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ) បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយអំពីលទ្ធផលការងារ និងទិសដៅការងារពាក់ព័ន្ធនឹងការ





ប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ នៅសណ្ឋាគារសូខាភ្នំពេញ ។

ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាអនុប្រធាន (គ.ស.ហ) បានធ្វើសេចក្តីរាយការណ៍សង្ខេបស្តីពីការងារប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យដោយបញ្ជាក់ថា ៖ គិតមកដល់ពេលនេះច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យថ្មី ត្រូវបានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការរួចហើយ ។ ទន្ទឹមនោះ ឯកឧត្តម ទេសាភិបាលធនាគារជាតិនៃកម្ពុជា ក៏បានថ្លែងអំណរគុណចំពោះការចូលរួមយ៉ាងសកម្មរបស់ក្រុមការងារពាក់ព័ន្ធ ព្រមទាំងបណ្តាដៃគូរអន្តរជាតិដែលបានផ្តល់ការប្រឹក្សាយោបល់ពីជំនួយបច្ចេកទេសនានា ដើម្បីគាំទ្រដល់ការរៀបចំច្បាប់ និងការងារផ្សេងៗពាក់ព័ន្ធការងារប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យនៅកម្ពុជា ។

ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ.) ក៏បានអញ្ជើញធ្វើរបាយការណ៍ជំរាបជូនអង្គពិធីទាំងមូលផ្សាយស្តីពី« លទ្ធផលការងាររបស់ (អ.អ.ផ) ដោយបញ្ជាក់ថា ៖ លទ្ធផលដ៏ល្អប្រសើរដែលកម្ពុជាសម្រេចបានកន្លងមកនេះ គឺកើតឡើងដោយសារមូលហេតុសំខាន់ចំនួន ២ គឺ**ទី១**-ក្រសួង-ស្ថាប័នអនុវត្ត



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




ច្បាប់ ដែលមានការពាក់ព័ន្ធបានបង្កើតឱ្យមានក្រុមការងារប្រឆាំងការសម្អាតប្រាក់ប្រចាំក្រសួង-ស្ថាប័នរបស់ខ្លួន និងបានគាំទ្រកិច្ចសហការពេញលេញលើការអនុវត្តប្រយុទ្ធប្រឆាំងការសម្អាតប្រាក់នៅកម្ពុជា និង**ទី២**-អនុគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការសម្អាតប្រាក់បានផ្លាស់ប្តូរនូវវិធីសាស្ត្រការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ចំពោះបទល្មើស





នីមួយៗ ជាពិសេសគម្លាតការស៊ើបអង្កេតដល់ការសម្អាតប្រាក់ ចំពោះបទល្មើសនានាដែលមានហានិភ័យខ្ពស់ដល់ការអនុវត្តស្របតាមស្តង់ដារហៅកាត់ថា SOP ប្រឆាំងការសម្អាតប្រាក់ដែលត្រូវបានបង្កើតឡើងនៅតាមក្រសួង-ស្ថាប័ននីមួយៗ ។

អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ **សម្តេចក្រឡាហោម** បានថ្លែងអំណរគុណចំពោះបណ្តាប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍន៍ដែលកន្លងមកបានជួយគាំទ្រ និងជួយជ្រោមជ្រែងការងារប្រឆាំងនឹងការសម្អាតប្រាក់រហូតបានទទួលលទ្ធផលមកដល់ពេលបច្ចុប្បន្នតាមរយៈការផ្តល់ជំនួយបច្ចេកទេស និងលិខិតគតិយុត្តដែលមានការពាក់ព័ន្ធ ។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានស្នើដល់តំណាងអង្គទូត និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលមានវត្តមានក្នុងកិច្ចប្រជុំនេះបន្តផ្តល់នូវកិច្ចសហការ និងការគាំទ្របន្ថែមទៀតដល់ប្រទេសកម្ពុជាលើ ២ចំណុចគឺ **ទី១**- សូមបន្តជួយគាំទ្របន្ថែមទៀតនូវបច្ចេកទេសក្នុងការប្រឆាំងការសម្អាតប្រាក់ជាពិសេសតាមរយៈការពង្រឹងសមត្ថភាពបច្ចេកទេសរបស់យន្តការប្រឆាំងការសម្អាតប្រាក់ ដើម្បីសម្រេចទិសដៅការងាររួម ដើម្បីឱ្យការងារនេះមានប្រសិទ្ធភាព ចំណុច **ទី២**-ជួយពាំនាំនូវសមិទ្ធផលការងារដែលកម្ពុជាសម្រេចបាន ទាំងលើកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តទាំងផ្នែកនយោបាយ ផ្នែកបច្ចេកទេសដល់ប្រទេស និងរដ្ឋាភិបាលរបស់ខ្លួន ៕



**៣កុំ** ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## « ដោះស្រាយបញ្ហាគ្រឿងញៀន





នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ក្រោមប្រធានបទ «**ដោះស្រាយបញ្ហាគ្រឿងញៀនក្នុងវិបត្តិសុខភាព និងមនុស្សធម៌** » ដែលប្រារព្ធនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសនានាប្រចាំកម្ពុជា ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ សរុបប្រមាណ ៣០៩៥នាក់ ។

ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញអានសារលិខិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ផ្ញើជូនជនរួមជាតិ ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ មិថុនា ឆ្នាំ២០២២ ដោយមានខ្លឹមសារថា៖ ជំងឺឆ្លងរាតត្បាតកូវីដ-១៩ ដែលបាន និងកំពុងកើតមានឡើង រួមជាមួយនឹងការផ្ទុះឡើងនៃសង្គ្រាមនៅប្រទេសអ៊ុយក្រែន



៣គារពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ២៦ មិថុនា ឆ្នាំ ២០២២ ក្រោមប្រធានបទ ក្នុងវិបត្តិសុខភាព និងមនុស្សធម៌ »



ក្នុងរយៈពេលជិត៤ខែកន្លងមកនេះ បាន និងកំពុងធ្វើឱ្យពិភពលោក និងមនុស្សជាតិយើងទាំងមូលទទួលរងនូវផលប៉ះពាល់ ទាំងដោយផ្ទាល់ និងដោយប្រយោល យ៉ាងធ្ងន់ធ្ងរបំផុត ។ ក្នុងនោះប្រក្រតីភាពនៃដំណើរការសេដ្ឋកិច្ច វប្បធម៌ សង្គម និងជីវភាពសង្គម ក៏ដូចជាសុខភាពសតិ

៣៧





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ៣៦

**ទិវាអន្តរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន...**

អារម្មណ៍ ផ្លូវកាយ ផ្លូវចិត្តរបស់បុគ្គល ត្រូវបានធ្លាក់ចុះ ប្រែប្រួល និងកែប្រែ ទម្លាប់ គួរឱ្យកត់សម្គាល់ ។ ជាមួយនេះការងារ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាការ ដោះស្រាយនូវបញ្ហាផ្សេងៗដែលពាក់ព័ន្ធ និងគ្រឿងញៀនក៏បាន និងកំពុងប្រឈម ជាមួយនឹងការលំបាកជាច្រើន ដូចវិស័យ ផ្សេងៗផងដែរ ។ ក្នុងន័យនេះប្រធានបទ របស់អង្គការ **យូ អិន អូ ឌី ស៊ី** (UNODC) ក្នុងឆ្នាំនេះ គឺមានគោលបំណងរំពាវនាវ លើកទឹកចិត្ត និងជំរុញដល់បណ្ដារដ្ឋជា សមាជិកទាំងអស់ ឱ្យបន្តផ្ដោតការយក ចិត្តទុកដាក់បន្ថែមទៀត ក្នុងការដោះស្រាយ បញ្ហាគ្រឿងញៀនឱ្យកាន់តែមានប្រសិទ្ធ ភាពដោយផ្អែកលើគោលការណ៍សុខភាព និងមនុស្សធម៌ជាមូលដ្ឋានចម្បង ។

សារលិខិត **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** បានបញ្ជាក់ទៀតថា៖ រាជរដ្ឋាភិបាល ក៏បានបន្តដាក់ចេញនិងអនុវត្តនូវយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៧ នៅទូទាំងប្រទេសយ៉ាងមានប្រសិទ្ធភាព ដោយបង្ក្រាបបទល្មើសគ្រឿងញៀនធំៗជាច្រើនករណី ចាប់យកវត្ថុតាងជាគ្រឿងញៀនបានជាច្រើនរយគីឡូក្រាម និងសារធាតុគីមីផ្សំគ្រឿងញៀនជាច្រើនតោន រួមជាមួយវត្ថុតាងផ្សេងៗជាច្រើនទៀត ។

សមិទ្ធផលទាំងនេះគឺជាការខិតខំប្រឹងប្រែងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់របស់សមត្ថកិច្ច និងមន្ត្រីបម្រើការងារក្នុងវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមជាមួយវិស័យឯកជន សាសនា អង្គការមនុស្សធម៌ជាតិ-អន្តរជាតិ វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀតរបស់



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល






ឃើងដែលជាសក្ខីភាពបង្ហាញពីការប្ដេជ្ញាយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាសេនាធិការ ក្នុងការដោះស្រាយបញ្ហាគ្រឿងញៀនដោយប្រកាន់យកនូវតុល្យភាពរវាងបញ្ហាសុខភាពមនុស្សធម៌ និងវិធានការច្បាប់ ព្រមទាំងចាត់ទុកអ្នកប្រើគ្រឿងញៀន គឺជាជនរងគ្រោះដែលត្រូវទទួលបានការយកចិត្តទុកដាក់ព្យាបាល ស្ដារនីតិសម្បទារ ជាជាងទទួលនូវការចោទប្រកាន់តាមផ្លូវច្បាប់ ស្របតាមប្រធានបទប្រចាំឆ្នាំរបស់អង្គការ **យូ អិន អូ ឌី ស៊ី** ដោយលើកលើគោលការណ៍សុខភាព និងមនុស្សធម៌ជាមូលដ្ឋាន បើទោះបីស្ថិតក្នុងកាលៈទេសៈលំបាក និងប្រឈមយ៉ាងណាក្ដី ។

នៅក្នុងសារលិខិត **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ក៏បានអំពាវនាវដល់គ្រប់ក្រសួង-ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ វិស័យសាសនា វិស័យឯកជន អង្គការជាតិ-អន្តរជាតិ និងបងប្អូន កូនក្មួយ ចៅៗជាជនរួមជាតិទាំងអស់ ពិសេសមាតាបិតា និងអាណាព្យាបាល សូមបន្តចូលរួម និងគាំទ្រឱ្យបានកាន់តែសកម្មថែមទៀត ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី**៧** របស់រាជរដ្ឋាភិបាលកម្ពុជា និងរួមគ្នាបន្តទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ តាមរយៈការអនុវត្តវិធានការសុខាភិបាល និងបន្តចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ដូសជំរុញឱ្យបានគ្រប់ៗគ្នា ។

អញ្ជើញមានប្រសាសន៍ក្នុងពិធីនោះ **សម្ដេចក្រឡាហោម** បានបញ្ជាក់ថា៖ ការប្រារព្ធពិធី ដ៏មានសារៈសំខាន់នេះត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ក្រោមប្រធានបទផ្សេងៗក្នុងគោលបំណងបន្ដដាស់តឿន ក្រើនរំលឹកដល់ជនគ្រប់រូបឱ្យយកចិត្តទុកដាក់ និងស្វែងយល់ឱ្យបានកាន់តែច្បាស់ ថែមទៀតពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ក៏ដូចជាក្នុងគោលបំណងបន្តអំពាវនាវ និងជំរុញឱ្យមានការចូលរួម និងគាំទ្រកាន់តែសកម្មថែមទៀត ក្នុងគ្រប់សកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងដោយផ្ទាល់ និងដោយប្រយោល ។

**សម្ដេចក្រឡាហោម** បានថ្លែងនូវការអរគុណ និងកោតសរសើរដោយស្មោះចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង-ស្ថាប័ន-អង្គភាពជាសមាជិក ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក៏ដូចជាកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានយកចិត្តទុកដាក់ និងអនុវត្តយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ។

ជាមួយគ្នានេះ **សម្ដេចក្រឡាហោម** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះក្រសួង-ស្ថាប័ន-អង្គភាពពាក់ព័ន្ធ អង្គការ-សមាគមជាតិ-អន្តរជាតិ វិស័យសាសនា វិស័យឯកជន សប្បុរសជនបណ្ដាប្រទេសជាមិត្ត ពិសេសបងប្អូនប្រជាពលរដ្ឋទូទៅ ក៏ដូចជានិស្សិត និងសិស្សានុសិស្សទាំងអស់ដែលបានចូលរួម និងគាំទ្រយ៉ាងពេញទំហឹងទាំងក្នុងពេលកន្លងមក ក៏ដូចជាពេលបច្ចុប្បន្ន រហូតធ្វើឱ្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ពិសេស ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ទាំង៦ ដំណាក់កាលរបស់រាជរដ្ឋាភិបាលដំណើរទៅបានដោយរលូន និងទទួលបានលទ្ធផលជោគជ័យគួរជាទីមោទនៈ ។

**សម្ដេចក្រឡាហោម** បានមានប្រសាសន៍សង្កត់ធ្ងន់ថា៖ ការបំភ្លេច ឬការមិនយកចិត្តទុកដាក់លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក៏អាចធ្វើឱ្យមានការ





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សម្តេចក្រឡាហោម ទទួលជួបពិភាក្សាការងារជាមួយ ឯកអគ្គរដ្ឋទូត កាណាដា ប្រចាំប្រទេស កម្ពុជា ឡាវ និង ថៃ



នារសៀលថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០២២កន្លងមកនេះ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យលោកជំទាវបណ្ឌិត **សារ៉ាស់ ថេយល័រ** (Sarah Taylor) ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំប្រទេសកម្ពុជា ឡាវ និងថៃ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ។

ក្នុងជំនួបពិភាក្សានោះ **សម្ដេចក្រឡាហោម** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជារួមរវាងកម្ពុជា និងកាណាដា ហើយថ្វីត្បិតតែភាគីទាំងពីរពុំមានកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើនក៏ពិតមែន ក៏ប៉ុន្តែប្រទេសទាំងពីរមានទំនាក់ទំនងជាមួយគ្នាល្អ ។ ទន្ទឹមនេះ **សម្ដេចក្រឡាហោម** ក៏បានថ្លែងអំណរគុណចំពោះ កាណាដា ដែលបានរួមចំណែកដល់ដំណើរការស្វែងរកសន្តិភាពការអភិវឌ្ឍរបស់ប្រទេសកម្ពុជា រួមទាំងការទទួលយកនូវជនភៀសខ្លួននៅកម្ពុជា ទៅកាន់ប្រទេសកាណាដា នៅក្នុងសម័យដែលប្រទេសកម្ពុជាធ្លាក់ក្នុងភ្លើងសង្គ្រាម ។

លើសពីនេះទៀត **សម្ដេចក្រឡាហោម** ក៏បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់កាណាដា មកដល់សហគមន៍អាស៊ាននៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ព្រមជាមួយនោះ **សម្ដេចក្រឡាហោម** ក៏សង្ឃឹម និងជឿជាក់ថាភាគីទាំងពីរនឹងខិតខំស្វែងរកនូវវិធីក៏ដូចជាឱកាសក្នុងការបង្កើននូវកិច្ចសហប្រតិបត្តិការលើវិស័យទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ រួមមានវិស័យសន្តិសុខ និងការងារកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ជាការឆ្លើយតប **លោកជំទាវបណ្ឌិត** ឯកអគ្គរដ្ឋទូតកាណាដា បានជម្រាបជូន **សម្ដេចថាលោកជំទាវ** ត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពប្រចាំនៅកម្ពុជា ថៃ និងឡាវប៉ុន្មានឆ្នាំមកហើយ ប៉ុន្តែដោយសារការរីករាលដាលជំងឺកូវីដ-១៩ ទើបពេលនេះ **លោកជំទាវ** មានឱកាសជួបជាមួយនឹង**សម្ដេច** ។

**លោកជំទាវ** ក៏បានយកឱកាសនេះសម្ដែងនូវការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលគ្រប់គ្រងបានល្អ



**៣ការពារ** ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:04 AM







ប្រសើរនូវជំងឺឆ្លងកូវីដ-១៩នេះ ជាពិសេស គឺយុទ្ធនាការចាក់វ៉ាក់សាំង ព្រមទាំងការផ្តល់នូវការចាក់វ៉ាក់សាំងនេះ ទៅដល់ជនបរទេសដែលស្នាក់នៅ និងបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ ។

**លោកជំទាវ** ក៏បានថ្លែងអំណរគុណក្រសួងមហាផ្ទៃ ដែលបានយកចិត្តទុកដាក់ចំពោះសំណើក៏ដូចជាជួយសម្រួលដល់ជនបរទេស រួមទាំងពលរដ្ឋកាណាដា នៅក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ ពិសេសបានទទួលការលើកលែងការដាក់ពិន័យចំពោះការស្នាក់នៅហួសទិដ្ឋាការក្នុងរយៈពេលនៃការផ្ទុះឡើងនៃជំងឺឆ្លងដ៏កាចសាហាវនេះ ។

**លោកជំទាវ** ក៏សង្ឃឹមជឿជាក់ដែរថា ខណៈពេលដែលជំងឺកូវីដ-១៩ មានស្ថានភាពធូរស្រាលនេះ ការផ្លាស់ប្តូររវាងប្រជាពលរដ្ឋនៃប្រទេសទាំងពីរក៏ដូចជាពលរដ្ឋខ្មែរ ដែលមានសញ្ជាតិកាណាដា ផងនោះនឹងមានការធ្វើដំណើរទៅមកប្រទេសទាំងពីរកើនឡើងវិញ ។

ពាក់ព័ន្ធក្នុងការពង្រីកនូវកិច្ចសហប្រតិបត្តិការលើវិស័យដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ **លោកជំទាវ** បានបង្ហាញនូវការគាំទ្រ និងអះអាងថានឹងខិតខំធ្វើយ៉ាងណាបង្កើនកិច្ចសហការលើការងារដ៏មានសារៈសំខាន់ទាំងពីរនេះសំដៅធ្វើយ៉ាងណាខិតខំរួមចំណែកទប់ស្កាត់នូវបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស គឺបទល្មើសគ្រឿងញៀន ដែលជាបទល្មើសមួយមានចរិតដ៏ស្មុគស្មាញ ។ ដោយឡែកពាក់ព័ន្ធនិងការងារកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ **លោកជំទាវ** ក៏បានជម្រាបជូន **សម្តេច** អំពីការខិតខំស្វែងរកឱកាសក្នុងការផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធទៅនឹងការងារខាងលើនេះព្រោះ កាណាដា ក៏ជាប្រទេសមួយដែលមានបទពិសោធន៍យូរឆ្នាំនៅលើការងារនេះ ។



**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/bgot/

តមកពីទំព័រ ៣៨

## ទិវាអន្តរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន...



ធ្លាក់ចុះនូវរាល់សកម្មភាពពាក់ព័ន្ធនឹងការ ររបរំផុញផ្សាយ ដែលធ្វើឱ្យបងប្អូនប្រជាពលរដ្ឋមួយចំនួន ពិសេសក្នុងចំណោមក្រុមគោលដៅជាយុវជនប្រឈមខ្ពស់ ងាយធ្លាក់ទៅក្នុង អន្ទាក់នៃបញ្ហាគ្រឿងញៀន ប៉ុន្តែយើងមិនត្រឹមតែមិនបំភ្លេច ឬទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយឡែកប៉ុណ្ណោះទេ **ផ្ទុយទៅវិញក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើនការយកចិត្តទុកដាក់ និងពង្រឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនជាប់ជាប្រចាំ ពិសេសក្រោមគោលនយោបាយចាក់គ្រោចចាក់សោរ១០០% របស់សម្តេចតេជោនាយករដ្ឋមន្ត្រី បានធ្វើឱ្យសមត្ថកិច្ចមានលទ្ធភាព យ៉ាងច្រើនក្នុងការបន្តសកម្មភាពរបស់ខ្លួនធ្វើការស្រាវជ្រាវរៀបរអង្កេត និងកំណត់មុខសញ្ញាបោកលានដល់ការបង្ក្រាប និងវាយបំបាក់នូវរាល់ល្បិចកលថ្មីៗរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀនធំៗ ដែលព្យាយាមធ្វើចរាចរគ្រឿងញៀនឆ្លងកាត់ និងប៉ុនប៉ងប្រើប្រាស់កម្ពុជាធ្វើជាទីតាំងកែច្នៃ ផលិតគ្រឿងញៀនខុសច្បាប់។** ជាក់ស្តែងក្នុងដំណាក់កាលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ខ្លាំង គឺឆ្នាំ២០២០ និងឆ្នាំ២០២១ សមត្ថកិច្ចអនុវត្តច្បាប់របស់យើងស្រាវជ្រាវរកឃើញ និងបង្ក្រាបបាន១០.៤១១ ករណី ក្នុងឆ្នាំ២០២០ និង ៦.៣០៨ ករណី ក្នុងឆ្នាំ២០២១ ឃាត់ខ្លួនជនសង្ស័យបានចំនួន២១.៥៦៦នាក់ ក្នុងឆ្នាំ២០២០ និងចំនួន ១៣.៩៧៩នាក់ ក្នុងឆ្នាំ២០២១ ព្រមទាំងរឹបអូសគ្រឿងញៀនគ្រប់ប្រភេទបានចំនួន ៣តោន ៩៧៥គក្រ ៩៩៨ក្រ ក្នុងឆ្នាំ២០២០ និងចំនួន ៤តោន ៦៨៩គក្រ ៦១១,៤៧ក្រ ក្នុងឆ្នាំ២០២១ ។


## ព្យាបាល និងដាក់ធ្មេញមិនគិតថ្លៃ

**មន្ទីរពេទ្យ ១៦ ឧសភា** របស់នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដែលមានទីតាំងនៅភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

សូមជូនដំណឹងដល់កងកម្លាំងនគរបាលជាតិ និងប្រជាជនទូទៅទាំងអស់ឱ្យបានជ្រាបថា : **មន្ទីរពេទ្យ ១៦ ឧសភា** បានរៀបចំព្យាបាលធ្មេញដោយឥតគិតថ្លៃ ។

**ក្នុងនោះមាន :**

- **ដកធ្មេញ**
- **សំអាតធ្មេញ**
- **ប៉ះធ្មេញ**
- **ព្យាបាលធ្មេញ**

**ចំពោះ**មន្ត្រីនគរបាលជាតិគ្រប់អង្គភាពទូទាំងប្រទេសដែលចង់មកទទួលសេវាដាក់ធ្មេញមិនមានគិតថ្លៃអ្វីទាំងអស់ត្រូវមាន (***អត្តសញ្ញាណប័ណ្ណនគរបាល***) ។

*** បញ្ជាក់: ដោយឡែកប្រដាប់ធ្មេញទូទៅមានតំលៃដូចខាងក្រោម :**

*-តម្លៃធ្មេញធម្មតា ១គ្រាប់ ១០$ (តម្លៃទីផ្សារខាងក្រៅ ១គ្រាប់ ៣០$*

*-តម្លៃធ្មេញ Ceramic ១គ្រាប់ ៣០$ (តម្លៃទីផ្សារខាងក្រៅ១គ្រាប់ ៨០$*

*ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ : 092 645 171, 015 75 79 79*





## វេជ្ជបណ្ឌិត ញ៉ែម សុខន

**បន្ទប់ពិនិត្យ-ពិគ្រោះនិងព្យាបាលជំងឺទូទៅ**

**- ឯកទេសផ្នែកជំងឺទូទៅ និងរូបភាពវេជ្ជសាស្ត្រ**

មានពិនិត្យអេកូសាស្ត្រពណ៌ផ្នែក :

- សរីរាង្គក្នុងពោះមាន: ថ្លើម, ប្រមាត់, លំពែង, បំពង់បង្ហូរទឹកប្រមាត់, តម្រងនោម។
- សរីរាង្គភេទស្ត្រី: ស្បូន, ដៃស្បូន, និងពិនិត្យផ្ទៃពោះ សរីរាង្គក្រពេញទីរ៉ូអ៊ីដ : ពកក

**- មានបទពិសោធន៍ក្នុងការងារពិនិត្យ និងព្យាបាលជំងឺរយៈពេល ២០ឆ្នាំ ។**

**បញ្ចុះតម្លៃ ១០%**
សម្រាប់មន្ត្រីនគរបាលជាតិ





អាសយដ្ឋានផ្ទះលេខ១៣៨អឺសូន្យ ផ្លូវ២១៥ (នេរុហ៍) សង្កាត់វាលវង់ ខណ្ឌ៧ មករា រាជធានីភ្នំពេញ (ខាងត្បូងស្តុបផ្សារដេប៉ូចម្ងាយ៥០ម៉ែត្រ)

ទូរស័ព្ទ: 097 2666 215 / 012 848 917







តមកពីទំព័រ ៣២

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត...**

ប្រសាសន៍សង្កត់ធ្ងន់ទៅចំណុចសំខាន់ៗ ចំនួន៣ មកធ្វើការជំរុញវិស័យកីឡាបាល់ទះកម្ពុជាឲ្យមានការរីកចម្រើនបន្ថែមទៀតដែលក្នុងនោះ ៖

**ទី១**-ត្រូវបង្កើតកីឡាបាល់ទះនារី ដើម្បីបំពេញលក្ខខណ្ឌ អាចឲ្យកីឡាបាល់ទះនារីចូលរួមប្រកួតក្នុងស៊ីហ្គេមឆ្នាំ២០២៣ ដែលកម្ពុជាយើងធ្វើជាម្ចាស់ផ្ទះ ។ **ទី២**-ត្រូវបង្កើតឲ្យមានទីលានប្រកួតដែលមានលក្ខណៈស្របតាមស្តង់ដារអន្តរជាតិ និង**ទី៣**-ត្រូវបង្កើនការប្រកួតជាលក្ខណៈមិត្តភាពអន្តរជាតិ ដូចជាប្រទេសវៀតណាម ថៃ ទួរគី និងបារាំងជាដើម ដើម្បីបំប៉នបន្ថែមដល់ក្រុមជម្រើសជាតិកម្ពុជា ដោយធ្វើការអញ្ជើញគ្រូក៏ដូចជាកីឡាករអន្តរជាតិទាំងនោះមកប្រកួតនៅប្រទេសកម្ពុជាផ្ទាល់តែម្តង ។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ប្រធានសហព័ន្ធកីឡាបាល់ទះកម្ពុជា បានណែនាំឲ្យក្រុមកីឡាករបាល់ទះជម្រើសជាតិទាំងអស់ ត្រូវរក្សាសុខភាព រក្សាកម្លាំងឲ្យបានល្អជៀសវាងនូវគ្រឿងស្រវឹង ជាពិសេសត្រូវមានផែនការរក្សាសុខភាព និងកម្លាំងដើម្បីធ្វើការហ្វឹកហាត់ត្រៀមចូលរួមការប្រកួតនៅឆ្នាំ២០២៣ ដែលកម្ពុជាយើងធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាស៊ីហ្គេម លើកទី៣២ ។

ក្នុងឱកាសនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ និងជាប្រធានសហព័ន្ធកីឡាបាល់ទះកម្ពុជា បានឧបត្ថម្ភដល់ប្រតិភូគ្រូបង្វឹក និងក្រុមកីឡាករ ចំនួន ២៥នាក់ ក្នុងម្នាក់ៗទទួលបានថវិកាចំនួន ២០០ ដុល្លារ ផងដែរ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សិក្ខាកាមនគរបាលជាតិ ២០០នាក់ បានបញ្ចប់

## វគ្គបណ្តុះបណ្តាលជំនាញ សន្តិសុខផ្ទៃក្នុង និង ចរាចរណ៍ផ្លូវគោក




ឧត្តមសេនីយ៍ឯក ឌី វិជ្ជា អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អញ្ជើញជាអធិបតីក្នុងពិធី

នៅក្នុងពិធីបិទវគ្គបណ្តុះបណ្តាលបំប៉នជំនាញចរាចរណ៍ផ្លូវគោក និងជំនាញសន្តិសុខផ្ទៃក្នុង នៅសាលានគរបាលមិត្តភាពកម្ពុជា-វៀតណាម ដែលស្ថិតនៅខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ កន្លងមកនេះ ឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ បានស្នើដល់សិក្ខាកាមនគរបាលសន្តិសុខផ្ទៃក្នុង និងនគរបាលចរាចរណ៍ផ្លូវគោក ទាំងអស់ពេលត្រឡប់ទៅអង្គភាពវិញ គប្បីបំពេញការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ ដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រ ក៏ដូចជាយន្តការកំណែទម្រង់នគរបាលជាតិ និងការកសាងកម្លាំងរបស់ក្រសួងមហាផ្ទៃ ឲ្យកាន់តែល្អប្រសើរបន្ថែមទៀត ។

ឧត្តមសេនីយ៍ឯក អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ បានបញ្ជាក់ទៀតថា៖ ការដែលអគ្គស្នងការដ្ឋាននគបាលជាតិ








៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

ក៏ដូចជាក្រសួងមហាផ្ទៃ បានផ្ដល់វគ្គបណ្ដុះបណ្ដាលជំនាញនានាដល់កងកម្លាំងនគរបាលទាំងអស់ គឺដើម្បីបង្កើនជំនាញ សមត្ថភាព និងវិជ្ជាជីវៈរបស់កងកម្លាំងនគរបាលយើងក្នុងកិច្ចការងាររក្សាសន្តិសុខ សណ្ដាប់ធ្នាប់ ជូនដល់ប្រជាជន និងប្រទេសជាតិទាំងមូលផង និងសំដៅទាក់ទាញ សមានចិត្ត អ្នកវិនិយោគ ផងដើម្បីជំរុញការកសាង និងអភិវឌ្ឍសង្គមជាតិឱ្យបានការរីកចម្រើន ។









គួរបញ្ជាក់ដែរថា៖ វគ្គបំប៉ន ជំនាញសន្តិសុខផ្ទៃក្នុង និងវគ្គបំប៉នជំនាញចរាចរណ៍ផ្លូវគោក ជូនមន្ត្រីនគរបាលជាតិ សរុបចំនួន ២០០នាក់ ដែលសិក្សារយៈពេល៣ខែ ចាប់ពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ និងត្រូវបានបញ្ចប់ដោយជោគជ័យនាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ នេះ ។





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




## SK Teeth Whitening Powder

ជាប្រភេទម្សៅដុសធ្មេញឲ្យស សម្រាប់អ្នកដែលមិនមានពេលទំនេរច្រើន ។ ហើយក៏អាចប្រើជាមួយឈុត Home Kit សម្រាប់ប្រភេទធ្មេញលឿងខ្លាំងពីកំណើត ។ លក្ខណៈពិសេសរបស់វាគឺមានតួនាទីជួយសំអាតជាតិកំបោរលើធ្មេញបានយ៉ាងល្អ ។ ប្រើរយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។




## Set Luxury + Powder

ឈុតពិសេសសំរាប់ធ្មេញលឿងខ្លាំងពីកំណើត

-ប្រើបាន ២៤ ដង
-គុណភាពសល្បឿន គុណានិង២
-មានអនាម័យខ្ពស់ ការវិចខ្ចប់ខ្ពស់
-មានវិតាមីន C ការពារអញ្ចាញ
-មាន Florine ការពារធ្មេញពុក
-មាន Potassium nitrate ការពារស្រៀវ ៗ ស្រគាធ្មេញ
-ជួយធ្វើអោយធ្មេញភ្លឺរលោង សស្អាត កំចាត់កំនរកំបោរ និងស្នឹបខ្មៅៗ លើធ្មេញប្រើរយៈពេល ៨ថ្ងៃ ចាប់ផ្តើមឃើញធ្វើប្លែក ។




## SK Luxury Kit

ជាប្រភេទពន្លឺធ្វើអោយធ្មេញស ដែលមានមុខងារពិសេសៗ ជាច្រើនរួមបញ្ចូលគ្នាក្នុងប្រអប់ Luxury Kit តែមួយ ។ មានវីតាមីនជួយការពារធ្មេញ អញ្ចាញធ្មេញ និងការពារស្រៀវស្រគា។ Luxury Kit Design ឡើងយ៉ាងសាកសមបំផុតសម្រាប់មនុស្សសម័យថ្មី ផ្លែផ្ការជាមួយនិងបច្ចេកវិទ្យាទំនើប និងការវិចខ្ចប់ដ៏ស្រស់ស្អាត។ អាចធ្វើជាកាដូជូនមនុស្សជាទីស្រលាញ់ ។ ប្រើប្រាស់រយៈពេល៧ថ្ងៃឃើញលទ្ធផល។




## SK Home Kit Teeth Whitening

សម្រាប់ប្រភេទធ្មេញធម្មតាជាប្រភេទពន្លឺធ្វើអោយធ្មេញស ប្រើដោយខ្លួនឯងនៅផ្ទះ ដោយមិនចាំបាច់ចំណាយពេលវេលា Clinic សម្រាប់ប្រភេទធ្មេញលឿងធម្មតា មិនស្រៀវ មិនលឿងពីកំណើត ប្រើប្រាស់រយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។







## Madamk Menbrane Gel

ជួយផ្តល់សំណើមយ៉ាងល្អដល់ស្បែកមុខ
បំបាត់នូវបញ្ហា
-រមាស់ -ក្របាម -របកស្បែក -អាល




## Madamk Healing Set Membrane Gel Add Oil

ជាប្រភេទឡេឈាបថែរក្សា និង បំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ អាចំរុយ ហើយជួយផ្តល់សំណើមដល់ស្បែក និងជួយបំបាត់រាល់បញ្ហារមាស់ក្របាមខ្លាំង របកស្បែករោល ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និង ក្រាស់ឡើញវិញ ។

## Madamk Healing Set

ជាប្រភេទឡេឈាបថែរក្សា និងបំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺមន្តរលោង ការពារមុខជាំ អាចម៍រុយ និងជ្រួញ ហើយថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្ពឹងសរសៃក្របាមផងដែរ ។ លក្ខណៈពិសេសគឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នក ដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ ។

**ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឫស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839**




Madamk Aromatic Nourishing Face Oil

មានមុខងារ
-ជួយបំបាត់មុខក្រហម
-ជួយបំបាត់មុខស្តើងសរសៃក្រហម
-ជួយស្បែកមានជាតិទឹក ភ្លឺរលោងក្មេងជាងវ័យ
ចំពោះអ្នកមានអាយុលើសពី ៣០ឆ្នាំ ឡើងទៅប្រើ Oil
នេះពេលថ្ងៃវាជួយផ្តល់ជាតិទឹក អោយមុខក្មេងជាងវ័យ
និងពន្យាភាពចាស់ផងដែរ។

Madamk Hair Shampoo & Hair Conditioner

មុខងារ :
-ជួយបណ្តុះសក់
-ជួយព្យាបាលសរសៃសក់ដែលខូចខ្លាំង
-ជួយធ្វើអោយសក់ទន់រលោងក្រអូបនិងជួយអោយសក់រឹងមាំ
-លាងជំរះស្បែកក្បាលបានល្អ បំបាត់អង្គែ និងរមាស់







Madamk Advance Eye Essence

-ជាសេរ៉ូលាបភ្នែក វាមានតួនាទី២យ៉ាង ទី១
ព្យាបាល ទី២ បញ្ជោគភ្លាមៗ
-ជួយអោយភ្នែកបាត់ខ្មៅ បាត់ស្នាក់ បាត់ជ្រួញ
-លាបភ្លាមឃើញភ្នែកអន់ខ្មៅ អន់ជ្រួញ អន់ស្នាក់ភ្លាមៗ
២០-៣០% (លាងទឹកត្រលប់មកធម្មតាវិញ)
-លាបរយះពេល ៣ខែឡើង ចាប់ផ្តើមឃើញលទ្ធផល
-លាបចូលអស់មិនកក លាបច្រើនយ៉ាងណាក៏មិនកក
និងអាចលាបនៅកន្លែងណាដែលមានស្នាមជ្រួញបានផលដែរ។




Madamk Qwhite Body Lotion

ជាឡេលាបខ្លួនអោយស្បែក ស ចម្ងរលោង
វាមានតួនាទី ៣យ៉ាង :
ទី១ បញ្ជោគអោយ ស ភ្លាម
ទី២ ធ្វើអោយស្បែក ស ពីខាងក្នុងពិតប្រាកដ
ទី៣ ជួយការពារកំដៅថ្ងៃបានយ៉ាងល្អ។
(លាងទឹកត្រលប់មកធម្មតាវិញ)
-លាបចាប់ពី ៣ខែ ឡើងទើបឃើញលទ្ធផល
ស្បែកសភ្លឺចេញពីក្នុង
-ស បែបស្បែកមានសុខភាពល្អ
-ជួយការពារកម្តៅថ្ងៃបានយ៉ាងល្អ SPF 25
រយះពេល ៣ខែឡើងចាប់ផ្តើមឃើញលទ្ធផល




Madamk Herbal Cream ជា Cream

ផ្សំពីផ្កា ឬសឈើ និងឡេវគុជខ្យងជួយ :
-បឺតជាតិពុល ជាតិថ្នាំគីមីពីក្រោមស្បែកមុខដែល
បន្សល់ពីផលិតផលចាស់
-បំបាត់អាល វីមុខ
-ជួយផ្ចិតរន្ធញើស
-ជួយអោយមុខភ្លឺរលោង






Madamk Healing Specail

ជាប្រភេទឡេលាបថែរក្សា និងបំប៉នស្បែកមុខ
វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ
អាចម៉ុយ ហើយជួយផ្តល់សំណើមដល់ស្បែក
និងជួយបំបាត់អាល វី មុនកប់ ជួយផ្ចិតរន្ធញើស
ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ
ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្រហម
បានផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយក
សារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពី
ផលិតផលចាស់ៗដែលមានសារធាតុថ្នាំ និងធ្វើអោយ
ស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើងវិញ។

Madamk Armpit Scrub ជាសាប៊ូដុះពេលងូតទឹក
-ជួយបំបាត់ក្លិនក្លៀកភ្លាមៗក្រោយពេលងូតទឹករួច
-ជួយអោយក្លៀក ស ចម្ង បាត់រុំពក មិនមានជាតិថ្នាំពេទ្យ
ដែលប៉ះពាល់ស្បែកក្លៀកទេ។

ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឫស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839

# ពិធីប្រគល់សញ្ញាបត្រជូនមន្ត្រីនគរបាលជាតិ

## បញ្ចប់ការសិក្សាជំនាញជាន់ខ្ពស់ និងថ្នាក់មធ្យមជំនាញស៊ើបការណ៍ខាងក្រៅ និងថ្នាក់មធ្យមជំនាញសន្តិសុខពីសាលាជាន់ខ្ពស់សន្តិសុខនៅប្រទេសវៀតណាម







នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ កន្លងមកនេះ បានរៀបចំពិធីបូកសរុបលទ្ធផលកម្មសិក្សាបញ្ចប់វគ្គ និងប្រគល់សញ្ញាបត្រ ជូនមន្ត្រីនគរបាលជាតិកម្ពុជា ចំនួន ៤៤រូប ក្នុងនោះមានស្រី ២រូប ដែលជាសិក្ខាកាមនគរបាលជាតិ ទើបបានបញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាលជាន់ខ្ពស់ និងថ្នាក់មធ្យម ជំនាញស៊ើបការណ៍ខាងក្រៅ និងវគ្គថ្នាក់មធ្យមជំនាញសន្តិសុខ នៅសាលាជាន់ខ្ពស់ប្រជាជន១ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមអធិបតីភាព ឧត្តមសេនីយ៍ឯក **ស ថេត** អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ និងលោកវរសេនីយ៍ឯក **ចឹង វ៉ាន់ទាន់** នាយកសាលាជាន់ខ្ពស់សន្តិសុខប្រជាជន១ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។



ពាក់ពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







សន្តិសុខ ប្រកបដោយជោគជ័យ នាពេលនេះ ។

ជាមួយនិងការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងរៀនសូត្រ រហូតទទួលបានជោគជ័យនាពេលបញ្ចប់វគ្គសិក្សារបស់សិក្ខាកាមនគរបាលកម្ពុជា ទាំង៤៤រូប ឯកឧត្តម អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ក៏បានត្រៀមរៀបចំគោលការណ៍ស្នើសុំទៅថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចជាក្រសួងមហាផ្ទៃ ដើម្បីធ្វើការលើកទឹកចិត្តជូនដល់សិក្ខាកាមទាំងអស់ឱ្យសមស្របតាមនិទ្ទេសដែលសិក្ខាកាមម្នាក់ៗទទួលបានផងដែរ ។

៦០

នៅក្នុងឱកាសនោះ ឧត្តមសេនីយ៍ឯក អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានមានប្រសាសន៍ស្វាគមន៍ និងអបអរសាទរចំពោះសិក្ខាកាមនគរបាលជាតិ ទាំង៤៤រូប ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល ជំនាញជាន់ខ្ពស់ និងថ្នាក់មធ្យម ជំនាញស៊ើបការណ៍ខាងក្រៅ និងវគ្គបណ្តុះបណ្តាលថ្នាក់មធ្យម ជំនាញ





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា


SINCE 1997
WWW.SOKHAGROUP.COM
E: SOKHASUN@SOKHAGROUP.COM
Cell: 012 / 070 8 7777 6
SOKHA
PRINTING HOUSE
#970, STREET BETONG, PHUM ROUNG CHAK,
SANGKAT PHNOM PENH THMEY, KHAN SEN SOK
WE KNOW,
WHAT YOU WANT
PRUelite
ABA
MAGAZINE • CATALOGUE • MENU • BOOKLET • ANNUAL REPORT • DIARY • NOTEBOOK • BROCHURE • FLYER • CORPORATE IDENTITY • FOLDER •
CALENDAR • PAPER BAG • PLASTIC BAG • ECO BAG • KEY CHAIN • HAND FAN • PARASOL/UMBRELLA • PEN • T-SHIRT • CAP • BAG • CAKE BOX
• MEDICAL BOX • POSTER • BANNER • BILLBOARD • PRE-PAID CARD • ID CARD • CHEQUE • SECURITY CARD


VHP
VHP Global Co., Ltd.
ទឹកបរិសុទ្ធធម្មជាតិ
ដើម្បីសុខភាព
1 ឆ្នាំ
កង្ហារ Hatari
MODEL: W2-340S MODEL: HWJ-110 MODEL: W2-320 MODEL: W2-340
HOT COLD 4 FILTER FUNCTION
HWJ-110 13L
W2-320 10L
W2-340 27L
W2-340s 11L
W2-160p 10L
W2-320WH 9L
W2-320H 9L
W2-1000 10L
WH-UP 200 90L/H
HU-800 90L/H
មុខងារតម្រង់ 4 FILTER FUNCTION
Sediment
ច្រោះកករ
(៣ខែប្តូរម្តង)
Pre -Carbon
ច្រោះសារធាតុគីមី
(៦ខែប្តូរម្តង)
Post -Carbon
បង្កើនរសជាតិទឹក
(៩ខែប្តូរម្តង)
UF-Membrane
កំចាត់មេរោគក្នុងទឹក
(១២ខែប្តូរម្តង)
មេដោយទទួលស្គាល់ពី អាមេរិក អឺរ៉ុប និងកូរ៉េ
ត្រូវការតំណាងលក់ផ្តាច់មុខតាមតំបន់នីមួយៗ
HYUNDAI
WACORTEC
ម៉ាស៊ីនចម្រោះទឹក
VHP Globle
www.hyundaiwater.com
023 6666 919 / 069 5000 86
ព័ត៌មានបន្ថែម
អាស័យដ្ឋាន : ផ្ទះលេខ ៣៨C ផ្លូវ ៤០៨ សង្កាត់ទួលទំពូង!!
ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល : info@vhp-global.com / facebook.com/vhp.global

22/5/23, 10:04 AM

# លក្ខណៈសម្បត្តិ ៦យ៉ាង ដែលភ្នាក់ងារ




ឧត្តមសេនីយ៍ឯក **អ៊ី សុខឃី** អគ្គស្នងការរងនគរបាលជាតិ ក្នុងឱកាសអញ្ជើញបិទវគ្គបំប៉នជំនាញភ្នាក់ងារសន្តិសុខឯកជន លើកទី៣៧ កាលពីល្ងាចថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២កន្លងមកនេះ បានផ្ដល់នូវការណែនាំចំនួន៦ចំណុចដល់ភ្នាក់ងារសន្តិសុខឯកជន បន្ទាប់ពីទទួលបានការបណ្ដុះបណ្ដាល ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការចូលរួមថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសង្គម ។



ឧត្តមសេនីយ៍ឯក លឹម សុខារស្មី ប្រធាននាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន







**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/bgot/

# សន្តិសុខឯកជន ត្រូវគោរពនិងអនុវត្តឲ្យបានជាប់ជាប្រចាំ








**ឧត្តមសេនីយ៍ឯក** អគ្គស្នងការរង បានបញ្ជាក់ថា៖ បច្ចុប្បន្ន ដើម្បីឲ្យភ្នាក់ងារសន្តិសុខឯកជន មានសមត្ថភាពពេញលេញក្នុងការចូលរួមចំណែកថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ បាននិងកំពុងយកចិត្តទុកដាក់ធ្វើយ៉ាងណាឲ្យភ្នាក់ងារសន្តិសុខឯកជនទាំងអស់ត្រូវមានចំណេះដឹង វិជ្ជាជីវៈ ក្រមសីលធម៌ ដើម្បីលើកកម្ពស់ផលវិស័យនេះឲ្យមានការរីកចម្រើនជាបន្តបន្ទាប់ដែលក្នុងនោះភ្នាក់ងារសន្តិសុខឯកជនទាំងអស់ត្រូវបំពេញភារកិច្ចដោយគោរពតាមលក្ខណ:សម្បត្តិទាំង៦យ៉ាងគឺ ៖

**ទី១**- ត្រូវមានឥរិយាបថក្នុងការចូលរួមធ្វើការងារ ដោយប្រកាន់យកអ្វីដែលជាការត្រឹមត្រូវក្រោយទទួលការបណ្តុះបណ្តាលជំនាញពីគ្រូឧទ្ទេសនាមដែលមានបទពិសោធន៍ជាមន្ត្រីនគរបាលយុត្តិធម៌ និងជាថ្នាក់ដឹកនាំនគរបាលជាតិ។

**ទី២**- គោរពឲ្យបាននូវលក្ខណ:សម្បត្តិជាភ្នាក់ងារសន្តិសុខឯកជន ត្រូវមានវិន័យ ក្រមសីលធម៌ ប្រើប្រាស់ឯកសណ្ឋានសន្តិសុខឯកជន និងសម្ភារ:បំពាក់ឲ្យបានគ្រប់គ្រាន់ ។

**ទី៣**- ភ្នាក់ងារសន្តិសុខឯកជន មិនមែនត្រឹមតែបម្រើការងារដល់ក្រុមហ៊ុន ឬគ្រឹះស្ថាននានាតែប៉ុណ្ណោះទេ គឺមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណ: ជាពិសេសការពារទ្រព្យសម្បត្តិ និងអាយុជីវិតប្រជាពលរដ្ឋផងដែរ ។

៥៩



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សកម្មភាពប្រតិភូ ស ម ន នាំយក
## ថវិកាផ្តល់ជូនដល់គ្រួសារសព សមាជិក-សមាជិកា ដែលទទួលមរណភាព និងបាត់បង់សមត្ថភាពការងារ



**ឧត្តមសេនីយ៍ឯក ស្អួន គឹមស៊ាន់** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ អញ្ជើញប្រគល់ថវិកា ស ម ន ជូនលោកស្រី យ៉ន ស្រ៊ុន ត្រូវជាម្ដាយសព លោកអនុសេនីយ៍ឯក ស្រេង សំណាង ។

**ឧត្តមសេនីយ៍ទោ ពាត ចាន់នី** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋានគ្រប់គ្រងអាវុធ ជាតិផ្ទុះ ប្រគល់ថវិកា ស ម ន ជូនដល់លោកស្រី កែវ រដ្ឋា ត្រូវជាភរិយាសពលោកវរសេនីយ៍ទោ អ៊ូ សុខា ។





**ឧត្តមសេនីយ៍ទោ ប្អាត សុធី** ប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ប្រគល់ថវិកា ស ម ន ជូនលោកស្រី ស៊ិន ដានី ត្រូវជាកូនបង្កើតសពលោកអនុសេនីយ៍ទោ ស៊ិន ស៊ាន ។

**ឧត្តមសេនីយ៍ត្រី ឃឹម សំអាន** លេខាធិការគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋានបុគ្គលិក ប្រគល់ថវិកា ស ម ន ជូនដល់លោក ផាន់ ចាន់ដារ៉ា ត្រូវជាកូនបង្កើតសពលោកវរសេនីយ៍ទោ ផាន់ ម៉ុង មន្ត្រីចូលនិវត្តន៍ ។



សូមលំអោនកាយរំលែកទុក្ខយ៉ាងក្រៀមក្រំ ចំពោះមន្ត្រីនគរបាលជាតិ ដែលបានពលីជីវិតក្នុងបេសកកម្មនានានៃបុព្វហេតុជាតិ មាតុភូមិ និង សូមបួងសួងឱ្យវិញ្ញាណក្ខន្ធបងប្អូន ចាប់បានទៅកាន់សុខគតិភព។



**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




***ឧត្តមសេនីយ៍ទោ ហ៊ិន សុធី*** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ប្រគល់ថវិកា ស ម ន ជូនលោកស្រី ជា ស៊ីនួន ត្រូវជាភរិយាសពលោកវរសេនីយ៍ត្រី ជា សុគន្ធ ។



***ឧត្តមសេនីយ៍ត្រី ភួច សាកល*** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តសៀមរាប ប្រគល់ថវិកា ស ម ន ជូនលោកស្រី ហង់ នេសាត ត្រូវជាភរិយាសពលោកអនុសេនីយ៍ទោ ឡេង វុទ្ធី ។



***វរសេនីយ៍ឯក ប៊ុត ហោង*** លេខាធិការគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តរតនគិរី ប្រគល់ថវិកា ស ម ន ជូនលោកអនុសេនីយ៍ត្រី ទិង សារ៉ី ដែលភរិយាទទួលមរណភាព ។

***ឧត្តមសេនីយ៍ត្រី ប៊ិច សោមសាខន*** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តក្រចេះ ប្រគល់ថវិកា ស ម ន ជូនលោកស្រី គ្រួច ចិន្តា ត្រូវជាភរិយាសពលោកអនុសេនីយ៍ត្រី ស៊ិន សាន មន្ត្រីចូលនិវត្តន៍ ។



***ឧត្តមសេនីយ៍ត្រី សេង គីមឃន*** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកណ្តាលប្រគល់ថវិកា ស ម ន ជូនលោកស្រី សុខ សោភា ត្រូវជាកូនស្រីបង្កើតសពលោកអនុសេនីយ៍ឯក សេង គីម ។



***ឧត្តមសេនីយ៍ត្រី ឡុង គីម*** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពត ប្រគល់ថវិកា ស ម ន ជូនលោកស្រី ជីវ ស៊ីណាត ត្រូវជាភរិយាសពលោកអនុសេនីយ៍ឯក សៅ សំអុល ។





**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# តើស្រីលង្កា ដោះស្រាយវិបត្តិ សេដ្ឋកិច្ចរបស់ខ្លួនដោយរបៀបណា?

រឿងរ៉ាវដ៏សោកសៅលើបញ្ហាវិបត្តិសេដ្ឋកិច្ចជាតិស្រីលង្កា បានក្លាយទៅជាវិញ្ញាសាមួយដ៏លំបាកបំផុតសម្រាប់លោកប្រធានាធិបតី និងនាយករដ្ឋមន្ត្រីបច្ចុប្បន្នដែលត្រូវប្រឈមមុខដោះស្រាយ។ វិបត្តិនេះត្រូវបានក្រុមសេដ្ឋវិទូជាតិមួយនេះបានលើកឡើងថា ជាបញ្ហាដ៏ធ្ងន់ធ្ងរបំផុតដែលគេមិនធ្លាប់ជួបប្រទះក្នុងរយៈពេលជាង៧ទសវត្សរ៍កន្លងមកនេះ ដែលយើងអាចនិយាយម្យ៉ាងទៀតថា ចាប់តាំងពីប្រទេសដែនកោះស្រីលង្កាបានទទួលឯករាជ្យភាពពីប្រទេសអង់គ្លេស កាលពីឆ្នាំ១៩៤៨ នោះ រហូតមក ។



ពាក់ព័ន្ធទៅនឹងស្ថានភាពសេដ្ឋកិច្ចមុនដាបនាពេលបច្ចុប្បន្ន បាននាំឱ្យមានការលើកឡើងនូវផ្សេងទស្សនៈខុសៗគ្នានៃបញ្ហាវិបត្តិដែលប្រទេសស្រីលង្កា កំពុងតែឆ្លងកាត់ ។ អ្វីដែលក្រុមអ្នកតាមដានលើស្ថានភាពស្រីលង្កាតាមទិដ្ឋភាពជាក់ស្តែងនោះត្រូវបានគេស្តីបន្ទោសលើការគ្រប់គ្រងខ្សោយផ្នែកឥណាទាន(បំណុល) និងការចាយវាយខុសខ្នងជាដើម ព្រោះថាប្រទេសនេះបានបុលខ្ទីពីខាងក្រៅ ដើម្បីយកមកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត លុះពេលកូវីដ-១៩ ផ្ទុះឡើងនៅក្នុងពិភពលោកក៏បានធ្វើឲ្យប៉ះពាល់យ៉ាងធំលើប្រទេសស្រីលង្កា ដោយសារតែប្រទេសនេះពឹងពាក់ខ្លាំងលើវិស័យទេសចរណ៍ ដូច្នេះនៅពេលដែលបិទខ្ទប់ដើម្បីប្រឆាំងនឹងជំងឺកូវីដ-១៩ នោះវិស័យទេសចរណ៍ត្រូវបានជាប់គាំងទាំងស្រុងក្នុងរយៈពេលជាង ២ឆ្នាំនេះ ។

ក្នុងបរិការណ៍កំពុងតែតានតឹងនេះ តើរដ្ឋាភិបាលក្រុងកូឡុំបូ មានវិធានការណ៍ដោះស្រាយរឿងនេះបែបណា?។ ដោយយោងតាមអគ្គទេសាភិបាលធនាគារកណ្តាលប្រទេសស្រីលង្កា លោក **ភី ណានដាឡាល់ វីរ៉ាសិង្ហេ** (P Nandalal Weerasinghe) បានថ្លែងប្រាប់ដល់បណ្តាញផ្សព្វផ្សាយប្រទេសអង់គ្លេសប៊ីប៊ីស៊ី(BBC)



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





ថា "**ប្រទេសស្រីលង្កា អាចនឹងចៀសផុតពីចលាចលសេដ្ឋកិច្ចបាន លុះត្រាតែប្រទេសនេះងាកទៅរកមូលនិធិរូបិយបណ្ណអន្តរជាតិឬហៅកាត់ (IMF) ដើម្បីស្តារស្រោចស្រង់កាន់តែឆាប់កាន់តែល្អបំផុត**"។ លោកបានបន្តទៀតថា "**ការយឺតយ៉ាវក្នុងការស្វះស្វែងរកជំនួយពីខាងក្រៅ ដើម្បីជួយស្រោចស្រង់នាពេលនេះ គឺជាកំហុសដ៏ធំមួយ**"។

កាលពីដើមឆ្នាំនេះ ប្រទេសស្រីលង្កាខ្លួនឯងធ្លាប់បានលើកឡើងថា ខ្លួនត្រូវការថវិកាប្រមាណជា**៥ពាន់លាន**ដុល្លារអាមេរិក ដែលជាជំនួយគាំទ្រចេញពីសហគមន៍អន្តរជាតិ ដែលក្នុងនោះរាប់បញ្ចូលទាំងមូលនិធិរូបិយបណ្ណអន្តរជាតិជាដើម។ ពាក់ព័ន្ធនឹងរឿងរ៉ាវដ៏សោកសៅផ្សេងនេះដែរ ប្រទេសស្រីលង្កាបានជាប់គាំងខ្លាំងទៅលើបំណុលអន្តរជាតិដែលមិនអាចដោះស្រាយរួចក្នុងរយៈពេលខ្លី ហើយរឿងនេះជាកិច្ចការប្រវត្តិសាស្ត្រដែលគេពុំធ្លាប់បានជួបប្រទះរយៈពេលកន្លងទៅ។

អគ្គទេសាភិបាលធនាគារកណ្តាលស្រីលង្ការូបនេះបានគូសបញ្ជាក់បន្ថែមទៀតថា "**ប្រសិនបើយើងបានធ្វើសេចក្តីសម្រេចចិត្តបានឆាប់រហ័សទៅរកមូលនិធិរូបិយបណ្ណអន្តរជាតិ(IMF) បានទាន់ពេលវេលានោះយើងនឹងអាចស្រាយបំណុលបានយ៉ាងងាយក្នុងរយៈពេល១ឆ្នាំ ហើយអោយយើងក៏មិនអាចជួបរឿងដ៏សោកសៅដូចសព្វថ្ងៃនេះដែរ**"។

បទអត្ថាធិប្បាយរបស់អគ្គទេសាភិបាលធនាគារកណ្តាលរបស់ប្រទេសស្រីលង្កាបានកើតមានឡើងខណៈដែលរូបលោកប្តេជ្ញាចង់ស្តារឡើងវិញនូវស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស គាប់ជួនគ្នាដែលប្រទេសរបស់លោកកំពុងតែឆ្លងកាត់នូវវិបត្តិសង្គ្រាមដ៏លំបាកលំបិនបំផុតដោយរាប់បញ្ចូលទាំងភាពខ្វះខាតប្រេងឥន្ធនៈប្រើប្រាស់ដ៏ខ្លាំងបំផុតការកើនឡើងនូវតម្លៃស្បៀងអាហារ ហើយនឹងភាពខ្វះខាតផ្នែកថ្នាំសង្កូវ ដែលសុទ្ធសឹងតែជាសមុដ្ឋាន(ដើមចម) នៃបញ្ហាទាំងអស់ដែលធ្វើឱ្យដួលរលំនូវសេដ្ឋកិច្ចទាំងមូល។

តាមការស្ទាបស្ទង់មតិមួយដែលធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិបានរកឃើញថា អ្នកស្រុកស្រីលង្កា ប្រមាណជា ២ភាគ៣ បានបង្ខំចិត្តកាត់បន្ថយការទទួលទានអាហារមកនៅត្រឹមតែ២ពេលប៉ុណ្ណោះ ហើយខ្លះទៀតនៅសល់តែមួយពេលប៉ុណ្ណោះក្នុងមួយថ្ងៃ។

៥៧



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




តមកពីទំព័រ ៥៦

## តើ ស្រីលង្កា ដោះស្រាយវិបត្តិសេដ្ឋកិច្ច...

កាលពីថ្ងៃចន្ទកន្លងទៅ មានមន្ត្រីមួយក្រុមដែលមកពីស្ថាប័នមូលនិធិរូបិយបណ្ណអន្តរជាតិ បានមកដល់ទីក្រុងកូឡុំបូ ដើម្បីចូលរួមពិភាក្សាលើការដោះស្រាយបញ្ហាវិបត្តិ ខណៈដែលលោកអគ្គទេសាភិបាលធនាគារកណ្តាលប្រទេសស្រីលង្កាក៏ចូលរួមផងដែរ ដោយមិនទាន់ឃើញមានរបាយការណ៍លំអិតអំពីការដោះស្រាយបញ្ហានេះនៅឡើយទេ គិតត្រឹមថ្ងៃចន្ទទី២០ ខែមិថុនា ឆ្នាំ២០២២ ។

តាមការឱ្យដឹងពីអគ្គទេសាភិបាលធនាគារកណ្តាលដែលបានលើកឡើងទៀតថា គេអាចនឹងត្រូវចំណាយពេលចរចាជាមួយនឹងមូលនិធិរូបិយបណ្ណអន្តរជាតិ (IMF) ដល់ទៅ២ខែបន្តទៀតទៅលើការបំពេញនីតិវិធីរកចរិកាសង្គ្រោះសេដ្ឋកិច្ចព្រោះមានភាពស្មុគស្មាញច្រើន ខណៈដែលប្រទេសនេះងាកទៅរកការខ្ចីលុយពីប្រទេសចិន ។ ជារួមបំណុលអន្តរជាតិសម្រាប់ប្រទេសស្រីលង្កាបានកើនឡើងដល់ទៅ១៥%ឯណោះ ។

ស្ថិតនៅក្នុងដំណាក់កាលគ្រោះអាសន្នផ្នែកសេដ្ឋកិច្ចនេះដែរ លោក **ទីរ៉ាសិង្ហេ** បានគូសបញ្ជាក់បន្ថែមទៀតថា **"ខ្ញុំជឿជាក់ថា ប្រទេសចិន គឺជាមិត្តល្អរបស់ប្រទេសស្រីលង្កា ដែលមិនសូវមាននីតិវិធីច្រើនដូចជាប្រទេសណាទាយកដទៃទៀតឡើយ"** ។

ដោយឡែកធនាគារពិភពលោកឯណោះវិញបានធ្វើការព្រមានថារឿងវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរមិនមែនមានត្រឹមតែប្រទេសស្រីលង្កាតែមួយប៉ុណ្ណោះនោះទេ ចំណែកប្រទេសកំពុងអភិវឌ្ឍចំនួន១២ទៀតក៏អាចនឹងមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រទេសស្រីលង្កាបច្ចុប្បន្ននេះដែរ ក្នុងរង្វង់១២ខែខាងមុខនោះ។

ឆ្លើយតបទៅនឹងការព្រមានពីសំណាក់ធនាគារពិភពលោកនេះដែរ ក្រុមអ្នកវិភាគមួយចំនួនបានលើកឡើងថា ភាគីរដ្ឋទាំងឡាយ ដូចជា ប្រទេសម៉ាល់ឌីវ ប្រទេសរ៉ូវ៉ាន់ដា រ៉ឺត្យូពី សេណេហ្គាល់ ក៏កំពុងតែស្ថិតនៅមាត់ជ្រោះមហន្តរាយលើវិស័យហិរញ្ញវត្ថុនេះដែរ ខណៈដែលគេមើលឃើញប្រទេសអេហ្ស៊ីប ប្រទេសហ្គាណា ហើយនិងប្រទេសប៉ាគីស្ថានក៏កំពុងតែវិលខ្លួនធ្លាក់ចូលងាយរងគ្រោះពីបញ្ហាវិបត្តិសេដ្ឋកិច្ចដែរនាពេលខាងមុខ ។

ងាកត្រឡប់មកមើលស្ថានភាពនៅក្នុងប្រទេសស្រីលង្កានេះវិញ ក្នុងស្ថានការណ៍ដែលកំពុងតែដុនដាបលើវិស័យថាមពលឥន្ធនៈនោះ លោករដ្ឋមន្ត្រីក្រសួងថាមពលប្រទេសស្រីលង្កា បានធ្វើការអំពាវនាវសូមឱ្យសហគមន៍អន្តរជាតិជួយក្នុងរង្វង់ទឹកប្រាក់ប្រមាណជា**៥០០លាន**ដុល្លារអាមេរិក ដើម្បីយកមកសង្គ្រោះវិស័យថាមពលជាបន្ទាន់សិន ស្របពេលដែលមន្ត្រីជាន់ខ្ពស់រូបនេះ បានអះអាងថា ប្រទេសស្រីលង្កានៅសល់ពេលតែត្រឹម៥ថ្ងៃប៉ុណ្ណោះ អាចនឹងអស់ប្រេងឥន្ធនៈប្រើប្រាស់ ហើយស្របពេលដែលប្រជាពលរដ្ឋមួយចំនួនមិនមានអគ្គិសនីប្រើប្រាស់នោះឡើយ ។

សូមបញ្ជាក់ផងដែរថា ប្រទេសស្រីលង្កាមានប្រជាពលរដ្ឋចំនួន ២២លាននាក់កំពុងតែរងគ្រោះដោយសារតែវិបត្តិសេដ្ឋកិច្ចជាតិដ៏ធ្ងន់ធ្ងរ រហូតដល់មានពលរដ្ឋជាច្រើននាក់ផ្សេងទៀត បាននឹងកំពុងតែត្រៀមធ្វើលិខិតឆ្លងដែន ដើម្បីចាកចេញក្រៅប្រទេសក្នុងគោលដៅ ដើម្បីស្វះស្វែងរកការងារធ្វើ និងចិញ្ចឹមជីវិតមួយគ្រាសិន។ ការឈរតម្រង់ជួរគ្នា ដើម្បីបំពេញបែបបទទម្រង់ធ្វើលិខិតឆ្លងដែននោះ បានបង្កឱ្យមានភាពយឺតយ៉ាវ ដោយសារតែកង្វះខាតផ្នែកមន្ត្រីធ្វើការងារលើកិច្ចការលិខិតឆ្លងដែន រហូតដល់ប្រធានផ្នែកធ្វើលិខិតឆ្លងដែនរអ៊ូរទាំថា មន្ត្រីរបស់ខ្លួនមានការហត់នឿយណាស់មិនអាចមានកម្លាំង



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



គ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋនោះទេ ។

គេនៅចងចាំបានថា កាលពីប៉ុន្មានសប្តាហ៍កន្លងទៅនេះមានការតវ៉ាពីសំណាក់មហាជនជាតិស្រីលង្កាស្ទើរពាសពេញផ្ទៃប្រទេស ដោយពួកគេទទូចឱ្យរដ្ឋាភិបាលក្រុងកូឡុំបូត្រូវដោះស្រាយបញ្ហាវិបត្តិសេដ្ឋកិច្ចប្រសិនបើដោះស្រាយមិនបានទេ គួរលាលែងចេញពីដំណែង។ ការតវ៉ារបស់ប្រជាពលរដ្ឋមិនដល់ពេលប៉ុន្មានថ្ងៃផង លោករដ្ឋមន្ត្រីហិរញ្ញវត្ថុ និងលោកនាយករដ្ឋមន្ត្រី ដែលចេញពីត្រកូលរាជ្យបក្សៈតែមួយរបស់ក្រុមគ្រួសារដឹកនាំដ៏មានឥទ្ធិពលនៅក្នុងប្រទេសស្រីលង្កាបានថយចេញពីតំណែងជាបន្តបន្ទាប់ដោយពួកគេបានលើកឡើងថា ដើម្បីទុកឱកាសឱ្យអនុជនរបស់គេបន្តវេនដោះស្រាយ ស្របពេលវិបាកសេដ្ឋកិច្ចកាន់តែធុនធាបទៅៗ ។

ពាក់ព័ន្ធនឹងរឿងថាមពលឥន្ធនៈឯណោះវិញម្តង បើតាម លោករដ្ឋមន្ត្រីក្រសួងថាមពល និងអគ្គិសនីលោក **កញ្ចនា វីជេសេកេរ៉ាក់** ( Kanchana Wijesekera ) បានលើកឡើងថា ប្រទេសស្រីលង្កាមិនអាចរំដោះបំណុលដែលលើសប្រមាណជា**៧២៥លាន**ដុល្លារអាមេរិកចំពោះក្រុមហ៊ុនផ្គត់ផ្គង់ និងដឹកជញ្ជូនបរទេស។

ដើម្បីដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខបែបនេះ ប្រទេសស្រីលង្កាកំពុងតែរង់ចាំយ៉ាងអន្ទះសារពីភាគីរដ្ឋាភិបាលឥណ្ឌាទៅលើឥណទានក្នុងទំហំទឹកប្រាក់ប្រមាណជា **៥០០លាន**ដុល្លារអាមេរិក ដើម្បីយកមកដោះស្រាយប្រេងឥន្ធនៈក្នុងរយៈពេលពីរបីសប្តាហ៍សិន ។ ប្រទេសឥណ្ឌា គឺជាអ្នកឧបត្ថម្ភគាំទ្រយ៉ាងសំខាន់មួយអំឡុងវិបត្តិហិរញ្ញវត្ថុ ដោយបានចាក់គ្រោងថវិកាជំនួយប្រមាណជា **៣ពាន់**លានដុល្លារអាមេរិក ក្នុងនោះរួមមាន **១ពាន់**លានដុល្លារអាមេរិក ជាប្រាក់កម្ចីសម្រាប់នាំផលិតផលចេញក្រៅប្រទេស ហើយថវិកាចំនួន **៤០០លាន**ដុល្លារអាមេរិកផ្សេងទៀត សម្រាប់ដោះស្រាយលើកិច្ចការដោះដូរមួយចំនួនដែលគេមិនបញ្ជាក់ច្បាស់លាស់នោះឡើយ ។

អ្វីដែលជាជម្រើសចុងក្រោយសម្រាប់រដ្ឋការក្រុងកូឡុំបូត្រូវដោះស្រាយ?

តាមបណ្តាញផ្សព្វផ្សាយអន្តរជាតិនានាបានលើកឡើងថាក្នុងស្ថានភាពដ៏តានតឹងនេះរដ្ឋបាលសាធារណៈរបស់ប្រទេសស្រីលង្កាបានបញ្ជាឱ្យមន្ត្រីទាំងឡាយបន្ថែមថ្ងៃឈប់សម្រាកដើម្បីយកពេលវេលាទៅដាំដំណាំជួយសម្រាលស្ថានភាពសេដ្ឋកិច្ចជាតិ រហូតដល់កន្លែងធ្វើការងារត្រូវបិទភ្លើងខ្លះ ក្នុងករណីដែលមិនចាំបាច់ត្រូវប្រើប្រាស់ចរន្តអគ្គិសនី ។ ក្នុងស្ថានភាពចំពោះមុខបែបនេះ ប្រជាពលរដ្ឋមិនសប្បាយចិត្តខ្លាំងរហូតឈានដល់ចេញមកធ្វើការតវ៉ាដើម្បីទាមទារសូមឱ្យប្រធានាធិបតីស្រីលង្កា លោក **ហ្គោតាបាយ៉ា រ៉ាចាបក្សស្ស:** ( Gota - baya Rajapaksa ) ចុះចេញពីតំណែងផងដែរ។

ចំណែកឯក្រសួងអប់រំជាតិវិញបានអំពាវនាវ សូមឱ្យសាលារៀនទាំងឡាយនៅទូទាំងប្រទេសត្រូវបន្តបិទទ្វាររយៈពេល២សប្តាហ៍បន្ថែមទៀត ដោយអនុញ្ញាតឱ្យរៀនតាមអនឡាញបាន ប្រសិនណាបើលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សមានប្រព័ន្ធអិនធឺណែតអាចចូលប្រើប្រាស់បាននោះ ។

អ្នកតាមដានសភាពការណ៍សេដ្ឋកិច្ចរបស់ប្រទេសស្រីលង្កាបានលើកឡើងថា រឿងវិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេសនេះ អាចនឹងត្រូវចំណាយពេលយូរអង្វែងបន្តទៀត ព្រោះថារហូតមកដល់ពាក់កណ្តាលខែមិថុនា គេពុំទាន់ឃើញសញ្ញាវិជ្ជមានណាមួយ អាចធូរស្រាលបាននោះទេ ខណៈដែលប្រទេសដែនកោះមួយនេះមានបំណុលរហូតដល់ទៅ**៥០ពាន់លាន**ដុល្លារអាមេរិក ចំពោះក្រុមប្រទេសជាឥណទាយក ដែលក្នុងនោះរួមមានចិន ឥណ្ឌា ជប៉ុន ហើយនឹងបំណុលសញ្ញាបណ្ណឯកជនជាច្រើនមុខផ្សេងទៀត ។

រហូតមកទល់នឹងពេលនេះ គេនៅមិនទាន់អាចសន្និដ្ឋានបានថា តើប្រទេសស្រីលង្កាត្រូវការពេលវេលាយូរប៉ុណ្ណានោះទេដើម្បីហោលឆ្លងកាត់នូវភាពទុក្ខសោកលើវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនមួយនេះ ។

ស្រាវជ្រាវ និង ប្រែសម្រួលដោយ
អនុសេនីយ៍ទោ **ប្រាក់ សម្ផស្ស**
ប្រភព៖ BBC/CNN/Reuters



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា









តមកពីទំព័រ ៥២

**លក្ខណៈសម្បត្តិ ៦យ៉ាង ដែលភ្នាក់ងារ...**

**ទី៤**- ត្រូវបង្កើតកិច្ចសហការជាមួយសមត្ថកិច្ច និងអាជ្ញាធរនៅមូលដ្ឋាន ៖ ជាពលរដ្ឋល្អ និងមហាជនល្អ ជាកម្លាំងជំនួយដ៏សំខាន់ដល់អាជ្ញាធរមានសមត្ថកិច្ច សហការបានល្អ ឆ្លើយតបបានទាន់ពេលវេលា ។ នៅពេលខ្លួនបានឃើញឬសង្ស័យលើសកម្មភាពល្មើសច្បាប់ណាមួយ មិនថាស្ថិតនៅក្នុងទីតាំងខ្លួនឈរជើងឬទីណានោះទេ ត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ច ឬមកនាយកដ្ឋានផ្ទាល់តាមរយៈលេខទូរស័ព្ទ ដើម្បីរួមគ្នាបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសបានទាន់ពេលវេលា ។

**ទី៥**-រួមគ្នាចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល គោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព។

**ទី៦**-ភ្នាក់ងារសន្តិសុខឯកជន ពិសេសនៅគោលដៅ កាស៊ីណូ បុរី ខុនដូរ អាផាតមិន សណ្ឋាគារ ផ្ទះសំណាក់ និងតំបន់សេដ្ឋកិច្ច ពិសេសត្រូវមានការហ្វឹកហាត់ជំនាញ បង្ការ និងពន្លត់អគ្គិភ័យ និងកិច្ចការងារតាមដានត្រួតពិនិត្យជនសង្ស័យ ដែលមានបំណងចង់ប្រព្រឹត្តបទល្មើសនៅគោលដៅរបស់ខ្លួន ជាពិសេសត្រូវយកចិត្តទុកដាក់សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចជាប់ជាប្រចាំ ។



យោងតាមរបាយការណ៍របស់ឧត្តមសេនីយ៍ឯក **លឹម សុខារស្មី** ប្រធាននាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន បានឲ្យដឹងថា៖ រហូតមកដល់បច្ចុប្បន្ននេះការបើកវគ្គបំប៉នជំនាញភ្នាក់ងារសន្តិសុខឯកជន បានចំនួន ៣៦លើក ដោយមាននាយនាយរងនគរបាលជាតិ នៃនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ចូលរួមសរុបចំនួន១៣០នាក់( ស្រី០៨នាក់) និងសិក្ខាកាម សរុបចំនួន ៦,៥៩៧នាក់



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









តមកពីទំព័រ ៤៨

**ពិធីប្រគល់សញ្ញាបត្រ ជូនមន្ត្រីនគរបាលជាតិ...**

ទន្ទឹមនេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក ក៏បានសំណូមពរស្នើសុំតាមរយៈលោក នាយកសាលាជាន់ខ្ពស់សន្តិសុខប្រជាជន១ សុំឱ្យពិនិត្យលទ្ធភាពបន្តជួយបើកវគ្គបណ្តុះបណ្តាលជំនាញខាងលើជូនដល់មន្ត្រីនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ នាពេលបន្តបន្ទាប់ទៀត សំដៅលើកកម្ពស់ចំណេះដឹង លើមុខជំនាញទាំងនេះឱ្យមានសមត្ថភាពខ្ពស់ ។

មានមតិឆ្លើយតបវិញ លោកវរសេនីយ៍ឯក នាយកសាលាជាន់ខ្ពស់សន្តិសុខប្រជាជន១ បានបញ្ជាក់ថា៖ នៅក្នុងរយៈពេលរៀនសូត្រនៅក្នុងសាលាពីសំណាក់សិក្ខាកាមនគរបាលជាតិកម្ពុជា គឺសាលាបានយកចិត្តទុកដាក់ជាទីបំផុត ដោយមានការរៀបចំការបង្ហាត់បង្រៀន ដោយគ្រូមានបទពិសោធន៍ មុខវិជ្ជាជំនាញត្រឹមត្រូវតាមកម្មវិធីសិក្សា គួបផ្សំការអញ្ជើញពីអង្គភាពពាក់ព័ន្ធ មកចូលរួមធ្វើបាឋកថាអនុវត្តដោយផ្ទាល់ ដើម្បីឱ្យសិក្ខាកាមទទួលបានចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងលើការងារជំនាញ និងការបង្ការបង្ក្រាបបទល្មើស ។

ដោយឡែកឆ្លើយតបចំពោះសំណូមពររបស់ ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ដែលបានស្នើសុំការបណ្តុះបណ្តាលផ្នែកជំនាញខាងលើបន្តទៀតនោះ គឺសាលានឹងពិនិត្យលទ្ធភាពចាត់បញ្ជូនគ្រូបង្គោល មកបង្ហាត់បង្រៀននៅទីនេះតែម្តង បើសិនមានការឯកភាពពីក្រសួងនគរបាលវៀតណាម និងក្រសួងមហាផ្ទៃកម្ពុជា ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្តេចក្រឡាហោម អញ្ជើញប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់ និស្សិតជ័យលាភីចំនួន ៦០៤នាក់ នៅ សាកលវិទ្យាល័យជាតិបាត់ដំបង





សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតជ័យលាភីសាកលវិទ្យាល័យជាតិបាត់ដំបង ស្ថិតក្នុងក្រុងបាត់ដំបង ខេត្តបាត់ដំបង សរុបចំនួន ៦០៤នាក់(ស្រី៣១០នាក់) កាលពីព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ កន្លងមកនេះ ។

ក្នុងសុន្ទរកថាស្វាគមន៍ ដែលអាន ដោយ ឯកឧត្តម **សុខ ឃន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិបាត់ដំបង បានឱ្យដឹងថា៖ សាកលវិទ្យាល័យជាតិបាត់ដំបង បានប្រែក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមស្មារតី **អនុក្រឹត្យលេខ១២៨៨អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យា**



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



***លើយជាតិបាត់ដំបង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល*** ។ គិតមកដល់ឆ្នាំសិក្សា ២០២១-២០២២នេះ សាកលវិទ្យាល័យមានកម្មវិធីអប់រំចំនួន៤៥ជំនាញ ក្នុងនោះ ថ្នាក់បរិញ្ញាបត្ររងមានចំនួន៥ជំនាញ ថ្នាក់បរិញ្ញាបត្រមានចំនួន២៩ជំនាញ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន៩ជំនាញនិងថ្នាក់បណ្ឌិតមានចំនួន២ជំនាញ។

ឯកឧត្តម សាកលវិទ្យាធិការបានឱ្យដឹងទៀតថា៖ គិតចាប់ពីឆ្នាំ២០០៨មកមានអតីតនិស្សិតចំនួនជាង ២០,០០០នាក់ជាធនធានសំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក្នុងស្ថាប័នសាធារណៈ និងឯកជនជាង៩០% ក្នុងវិស័យសំខាន់ៗដូចជា វិស័យអប់រំ សេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម ជីវចម្រុះ ទេសចរណ៍ ធនាគារ ច្បាប់ បដិសណ្ឋារកិច្ច បច្ចេកវិទ្យា និងសំណង់ស៊ីវិលជាដើម ។ បច្ចុប្បន្នសាកល



ឯកឧត្តម សុខ យន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិបាត់ដំបង

៦៣













តមកពីទំព័រ ៦២

## សម្តេចក្រឡាហោម អញ្ជើញប្រគល់.

វិទ្យាល័យជាតិបាត់ដំបង បាននឹងកំពុងធ្វើការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត សរុបចំនួន៣៩ ជំនាញឯកទេស ដែលនៅក្នុងឆ្នាំ២០២២នេះ សាកលវិទ្យាល័យមាននិស្សិតសរុបចំនួន ៤,៥៩៨នាក់ ស្រី ២,៧២២នាក់ ។



ដោយឡែកថ្ងៃនេះសាកលវិទ្យាល័យជាតិបាត់ដំបង បានរៀបចំពិធីប្រគល់សញ្ញាបត្រ ជូនដល់និស្សិតជ័យលាភីចំនួន ៦០៤នាក់ (ស្រី៣១០នាក់) ដែលមាននិស្សិតបរិញ្ញាបត្ររងចំនួន៥២នាក់ និស្សិតបរិញ្ញាបត្រមានចំនួន៤៨៤នាក់ និងនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៦៨នាក់ ។

អញ្ជើញសំណេះសំណាលក្នុងពិធីនោះ **សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ថា៖ ខ្ញុំនៅចាំថាក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ យើងនៅសេសសល់អ្នកចេះដឹងតិចតួចប៉ុណ្ណោះ ដែលទាមទារឱ្យយើងត្រូវតែខិតខំកៀរគរអ្នកទាំងនោះ ដើម្បីរៀបចំប្រព័ន្ធអប់រំរបស់យើងឡើងវិញ ដោយផ្តើមចេញពីពាក្យស្លោកថា « **អ្នកចេះច្រើនបង្រៀន អ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកអត់ចេះ** »



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







ប៉ុន្តែឥឡូវនេះយើងមានមន្ត្រីអប់រំ គ្រូបង្រៀនប្រកបដោយសមត្ថភាព និងវិជ្ជាជីវៈជាច្រើនម៉ឺននាក់ ដែលកំពុងបម្រើផ្តល់សេវាអប់រំគ្រប់កម្រិត ជូនសង្គមជាតិ និងប្រជាជនយើង ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍កត់សំគាល់ទៀតថា៖ តាមរបាយការណ៍របស់ ឯកឧត្តម សាកលវិទ្យាធិការ យើងឃើញថា ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាសាកលវិទ្យាល័យជាតិបាត់ដំបង បានអនុវត្តនូវគោលនយោបាយ និងសកម្មភាពយ៉ាងខ្ជាប់ខ្ជួន ដើម្បីលើកកម្ពស់ការបណ្តុះបណ្តាលជំនាញ ទាំងការសិក្សារបស់និស្សិត ទាំងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនរបស់យើង ជាពិសេសការផ្តោតលើការសិក្សាជំនាញកសិកម្ម វិទ្យាសាស្ត្រ និងបច្ចេកទេសដែលជាជំនាញអាទិភាព សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក៏ដូចជាការអនុវត្តគោលដៅសេដ្ឋកិច្ចឌីជីថលដែលទើបដាក់ចេញថ្មីៗនេះផងដែរ ។ ដោយមើលឃើញពីសារសំខាន់នៃវិស័យអប់រំដូចបានរៀបរាប់ខាងលើនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងកម្មវិធីនយោបាយគ្រប់នីតិកាលនៃរដ្ឋសភា ដោយបានផ្តល់អាទិភាពខ្ពស់លើ«**វិស័យអប់រំ**» ។ បន្ថែមពីលើនេះរាជរដ្ឋាភិបាលបានកំណត់គោលដៅជាយុទ្ធសាស្ត្រគឺ ការអភិវឌ្ឍ « **ប្រព័ន្ធអប់រំប្រកបដោយគុណភាព សីលធម៌ និងបរិយាបន្ន** » ផ្តោតសំខាន់លើវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការតម្រង់ទិស សម្រាប់ទីផ្សារការងារ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បន្តទៀតថា៖ ដើម្បីឈានទៅសម្រេចបាននូវលទ្ធផល ដូចបានលើកឡើងខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាសាកលវិទ្យាល័យបាត់ដំបង ត្រូវបន្តយកចិត្តទុកដាក់អនុវត្តកំណែទម្រង់ស៊ីជម្រៅលើការងារអាទិភាពសំខាន់ៗដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ១០ឆ្នាំរបស់ខ្លួនបន្ថែមទៀត ដែលក្នុងន័យនេះខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា៖ គណៈគ្រប់គ្រងមន្ត្រីអប់រំគ្រប់ថ្នាក់នឹងខិតខំពុះពាររាល់ឧបសគ្គ ដើម្បីបន្តអភិវឌ្ឍសាកលវិទ្យាល័យនេះឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ប្រកបដោយវិបុលភាពកិត្យានុភាព និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាថ្នាលបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាពទាំងកម្រិតជាតិ និងអន្តរជាតិ ។៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា


SOKIMEX INVESTMENT GROUP
ក្រុមហ៊ុន សុគីមិច អ៊ិនវេសមេន គ្រុប
SOKIMEX INVESTMENT GROUP CO., LTD.
SOKHA
សណ្ឋាគារ និងរមណីយដ្ឋានសុខា
Sokha Hotels & Resorts
+855 23 91 91 91
បូកគោ
ក្រុមហ៊ុនបូកគោហ្វាម ឯ.ក
Bokor Farm Co.,Ltd.
+855 88 2636358 | +855 88 9494614
SOKIMEX
ស្ថានីយប្រេងឥន្ធនៈសុគីមិច
Sokimex Petroleum Station
SOKHA
REAL ESTATE
ក្រុមហ៊ុនសុខារៀលអ៊ីស្ទេត ឯ.ក
Sokha Real Estate Co., Ltd.
+855 98 200 777
#22 Kramuon Sar,Sangkat Phsar Thmey 2, Daun Penh, Phnom Penh Cambodia
Tel: (855) 23 998 918,Fax: (855) 23 998 920| E-mail: info@skmig.com | Website: www.skmig.com